សមាគមខ្មែរ

# KHMER LOWELL

# ខ្មែរឡូវែល

មិនា-March 1997; Issue No. 2




**Board of Directors**

*Mr. Chanrithy Uong*
*President*
*Mr. Jem Chea*
*1st Vice President*
*Ms. Chantha Bin*
*2nd Vice President*
*Mr. Thel J. Sar*
*Secretary*
*Mr. Seng Jy*
*1st Treasurer*
*Ms. Sokha Diep*
*2nd Treasurer*
*Ms. Sithra Chan*
*Assistant Secretary*
*Mr. Michael Ben Ho*
*Mr. Chiem Huon*
*Mr. Pan So*
*Mr. Nick P. Mann*
*Mr. Chiv Peter In*
*Ms. Bophany Pheng*

**Legal Counsel**

*Joseph H. Sexton*

**Executive Director**

*Samkhann Khoeun*

**បុណ្យខួបឆ្នាំ ទី១០ នៃមជ្ឈមណ្ឌលកុមារ សមាគមខ្មែរ**

(2/17/87 - 2/19/97)

**A Ten year Anniversary Celebration of Komar Day Care Center - CMAA**

(2/17/87 - 2/19/97)

## Appreciating 10 years...

SUN/CHERYL A. MILLER



Betty Borden, former director of the Komar Day Care Center, and Samkhan Khoeun, executive director of the Cambodian Mutual Assistance Association, keep a watchful eye as, from left, Jonathan Soun, 4, Randy Hell, 3, Matthew Keo, 4, Sarin Ruom, 3, and Sophat Chhim, 5, play with a chalkboard. The Komar Day Care Center yesterday celebrated its 10th anniversary.

**A collaborative publication of the Cambodian Mutual Assistance Associatoin of Greater Lowell, Inc., (CMAA) the Cambodian American Voter League (CAVL), and the Khmer Cultural Institute (KCI)**

# *Acre Family Day Care*



14 Kirk Street

*Lowell, MA 01854*

*(508) 937-5899*



**ក្រសួងថែទាំកុមារនៃគ្រួសារសហគមន៍អេកឺរ៍ សូមជូនដំណឹងថាយើងមានប្រាក់មួយចំនួន សំរាប់ជួយផ្តល់ដល់គ្រួសារ ដែលប្រកបការងារមានកូនអាយុពី ៣-៩ឆ្នាំហើយមានការខ្វះខាតក្នុងការបង់ថ្លៃឈ្នួលអ្នកមើលក្មេង។**

មានគ្រួសារជាច្រើននៅក្នុងទីក្រុងឡូវែលបានជួបប្រទះបញ្ហាក្នុងការរកជួលអ្នកមើលកូន ពីព្រោះដោយមានកំរៃថ្លៃពេក ក៏ប៉ុន្តែក្រសួងយើងមានប្រាក់មួយចំនួន ដើម្បីសម្រួលបញ្ហានេះដោយយកកំរៃថោកល្មម ព្រមទាំងមានអ្នកថែទាំកុមារយកចិត្តទុកដាក់និងក្មេង និងមានការពិសោធន៏ខាងថែទាំក្មេង។ ដូច្នេះបើសិនលោកអ្នកចង់បានពត៏មានបន្ថែម សូមទាក់ទងលេខទូរស័ព្ទ **937-5899** ។

## ក្រសួងថែទាំកុមារនៃគ្រួសារសហគមន៍អេកឺរ៍អាចជួយៈ

- រកអ្នកមានការហ្វឹកហ្វឺន និងមានសញ្ញាប័ត្រហើយមានការពិសោធន៏ខាងថែទាំកុមារ
- ផ្តល់កម្មវិធីថែទាំកុមារនៅតាមផ្ទះ
- ផ្តល់ម្ហូបចំណីដោយអត់យកកំរៃ
- មានគ្រប់វេនម៉ោងធ្វើការ ( Full time, Part time, and second and Weekend shift )
- ផ្តល់អ្នកថែទាំកុមារចេះនិយាយភាសាខ្មែរ អង់គ្លេសនិងស្ពានិស្ស។ ការថែទាំកុមារតាមផ្ទះមានសឹងគ្រប់ទីកន្លែងនៅក្រុងឡូវែល។

ឥឡូវនេះក្រសួងយើងកំពុងមានកន្លែងទំនេទទួលមើលក្មេង ដូច្នេះសូមលោកអ្នកទូរស័ព្ទមកចុះឈ្មោះឆាប់ៗ ដើម្បីកុំឲ្យយឺតពេល។

**ក្រសួងថែទាំកុមារនៃគ្រួសារសហគមន៍អេកឺរ៍**

ACRE FAMILY DAY CARE CORPORATION

14 KIRK STREET

LOWELL, MA 01854

**937-5899**

កម្មវិធីនេះជ្រោមជ្រែងដោយកម្មវិធីសាមគ្គីភាពសហគមន៏ (Community Partnership Program)
នៃសាលាសាធារណៈទីក្រុងឡូវែល។

Learning together/growing together សិក្សាអប់រំរួមគ្នា ចំរើនរួមគ្នា

1. Why Do We Need Foster Home ---------------------------------------------------------------- 4
2. អំពីប្រាក់ជំនួយ "SSI" ចំពោះជនដែលមិនមានសញ្ជាតិជាអាមេរិកាំង ------------------ 5
3. ចេះតែថា ---------------------------------------------------------------- 7
4. បញ្ហាសង្គម ------------------------------------------ 7
5. Cambodian Women Speak: an interview with Sara Im and Chantha Bin. ----- 8
6. MTV's Hip Hop Black Culture and Cambodian Youth -------------------------- 14
7. វិបត្តិចំពោះក្មេងដែលបណ្តាលមកពីការឈ្លោះវាយតប់ក្នុងគ្រួសារ ------------------------------ 15
8. American Tobacco Companies Are Cashing In On Cambodia's Poor -------- 17
9. Building On A Dream: A Cambodian Cultural Center ------------------------- 18
10. ជួរក្តៅនូវតាមជនស្ទើរមើរមាក ------------------------------------------------------ 23
11. ប្រជាធិបតេយ្យ គឺជាអ្វី ------------------------------- 24
12. កាព្យបណ្តាំ ------------------------------------- 25
13. សន្តិភាព ---------------------------------------------------------------- 26



# ថ្នាក់បង្រៀនចូលសញ្ជាតិ
# Citizenship Class

FREE

រៀនរាល់ថ្ងៃសៅរ៍ ពីម៉ោង ១០ព្រឹក ដល់ម៉ោង ១២ថ្ងៃត្រង់

**Every Saturday Morning**
**10 AM - 12 Noon**

សូមអញ្ជើញទាក់ទង CMAA - 125 Perry Street; Lowell, MA 01852

Tel: (508) 454-4286 ។ សូមសួររក រ៉ាឌី ហ៊ុច

# Why Do We Need Foster Home?

The Department of Social Services provides services to families and children. The mission at DSS is to support and strengthen families, keeping families together whenever possible. DSS provides a full range of family support services, including counseling, day care, and parent aides. When families can not provide the necessary care and protection for their own children, DSS intervenes to ensure children's safety.

When a child can no longer be cared for by their family DSS intervenes in order to protect the child. If a child needs to leave their families home, DSS will first attempt to place the child with a family member. If no family member is available or not appropriate to take the child, DSS will then place the child in a foster home.

The Lowell DSS office, located at 33 E. Merrimack Street, provides services to Lowell as well as the seven surrounding communities. Therefore our foster homes are located throughout the greater Lowell area. When a child needs a foster home, certain factors are considered when a placement is trying to be found. We try to place children in foster homes of the same ethnic background as the child. We try to place sibling groups together. We try to keep children within their school districts. All of these factors are not always possible because of the shortage of foster homes we have. And children are places in a good foster home, which in fact didn't allow us to meet any of the above factors.

Placing children in foster homes is a daily occurrence in our office. If you were to walk through our office lobby on any given day you might see the older children sitting there. Then you might wonder why they have all sorts of bags and luggage surrounding them. These are the teenagers waiting to be placed. These teenagers might sit all day wondering where they will sleep that night. They might have just had a tough time in court, may be the court ordered them into a foster home, they have no idea where they will end up. An even tougher situation is that we might only be able to get them a foster home for one night on an emergency basis. This means they

**Continue from page 12**


## ការងារថ្មី! ការងារថ្មី! ការងារថ្មី!

យើងត្រូវការ អ្នកធ្វើការ ពាក់កណ្ដាលថ្ងៃ ឬពេញមួយថ្ងៃ

# WESTERN STAFF SERVICES

## មានការងារជាច្រើន

នៅក្នុងទីក្រុងឡូវែល (LOWELL) និងឆេមហ្វឺត(CHELMSFORD)

លោកអ្នកអាចចាប់ផ្ដើមធ្វើការក្នុងថ្ងៃនេះភ្លាម ហើយការងារនោះនឹងជាទីពេញចិត្តរបស់លោកអ្នកជាមិនខាន

កិច្ចការរកការងារជូនលោកអ្នករបស់យើងគឺ មិនគិតថ្លៃ ហើយយើងនឹងគាំទ្រ លោកអ្នក

អោយមានការធានាសុខភាព និងមានកម្រៃផ្សេងៗជាច្រើនទៀតយើងត្រូវការអ្នកធ្វើការចំនួន 40 នាក់ ជាបន្ទាន់!!!

ការដាក់ពាក្យសុំធ្វើការនៅអាស័យដ្ឋានលេខ

**60 CHELMSFORD ST., CHELMSFORD, MA 2ND FLOOR**

ពត៌មានបន្ថែមសូមទាក់ទង **TOM** ឬ **CHRISTINE** តាមទូរស័ព្ទលេខ: **(508) 244-9199**

# អំពីប្រាក់ជំនួយ "SSI" ចំពោះជនដែលមិនមានសញ្ជាតិជា អាមេរិកាំង

ច្បាប់ចេញថ្មីរបស់សហរដ្ឋអាមេរិកបានកែប្រែរបៀបរបប ដែលយើងធ្លាប់ បានផ្តល់ប្រាក់ចំនួយ S S I ( Supplemental Security Income) ដល់ជន ដែលពុំមានសញ្ជាតិជាអាមេរិកាំង(Noncitizens)។ ច្បាប់ថ្មីនេះនឹងអនុវត្តទៅលើអ្នកដែលបានទទួលលុយ S S I ហូរហែរួចមកហើយនិងអ្នកដែល កំពុងតែដាក់ពាក្យសុំលុយនេះ។

**តើច្បាប់ថ្មីនេះបាននិយាយដូចម្ដេចខ្លះ?**

តាមច្បាប់ថ្មីនេះ គឺអ្នកដែលមានសញ្ជាតិជាអាមេរិកាំង អ្នកដែលកើតក្នុងសហរដ្ឋអាមេរិក និងអ្នកដែលគ្មានសញ្ជាតិជាអាមេរិកាំងជំពូកខ្លះ និងត្រូវមានសិទ្ធិអាចទទួលលុយ S S I បាន។

តើអ្នកណាដែលអាចទទួលលុយ SSI បាននៅថ្ងៃទី ២២ ខែសីហា ឆ្នាំ១៩៩៦ (8/22/96) និងថ្ងៃបន្ទាប់មកទៀត? មនុស្សទាំងអស់នោះគឺ អ្នកដែលមានសញ្ជាតិជាអាមេរិកាំង ឬអ្នកដែលកើតក្នុងសហរដ្ឋអាមេរិកនេះ អ្នកដែលគ្មានសញ្ជាតិជាអាមេរិកាំង (Noncitizens) ហើយបានទទួលលុយ SSI ក្នុងថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៦ នឹងនៅបានទទួលរហូតដល់ពេលយើង S S A (Social Security Administration) ធ្វើការសើរើពិនិត្យសំណុំរឿងជាថ្មីឡើងវិញ (Case review) ។ សូមអានសេចក្តីពន្យល់ "តើលុយ S S I របស់លោកអ្នក និងត្រូវអស់នៅពេលណា?" នៅទំព័រក្រោយ។ អ្នកដែលគ្មានសញ្ជាតិជាអាមេរិកាំងហើយបានចូលមករស់នៅក្នុងសហរដ្ឋអាមេរិកដោយស្របច្បាប់ ក្នុងឋានៈជាប្រជាពលរដ្ឋអចិន្ត្រៃយ៍ (Permanent residence) ហើយបានធ្វើការបង់តាក់ (Tax payer) អោយរដ្ឋយ៉ាងហោចណាស់ក្នុងកំឡុងពេល១០ឆ្នាំ ឬ 40QCs (40 Qualifying Work Credits) ។ ដោយគិតរាប់ដូចច្នេះ ចំនួនឆ្នាំធ្វើការរបស់ប្តី ឬប្រពន្ធ ឬក៏ម្តាយឪពុក អាចគិតរាប់យកមកបញ្ចូលបង្គ្រប់ចំនួន១០ឆ្នាំ (40QC) បាន។ ចំនួន 40QC នេះ គឺសម្រាប់ប្រើយកមកសុំលុយ S S I ប៉ុណ្ណោះ ពុំមែនសម្រាប់សុំលុយ S S A (Social Security Benefit ) នោះទេ។ ចំនួនឆ្នាំធ្វើការ (QC) ក្រោយថ្ងៃទី៣១ ខែធ្នូឆ្នាំ១៩៩៦ នឹងមិនរាប់បញ្ចូលទេ បើប្តីឬប្រពន្ធ ឬឪពុកម្តាយអ្នកនោះ បានទទួលប្រាក់ជំនួយអ្វីមួយពីរដ្ឋាភិបាលសហរដ្ឋនាពេលនោះ។ អ្នកដែលគ្មានសញ្ជាតិជាអាមេរិកាំងដែលកំពុងតែបំរើក្នុងជួរកងទ័ពសហរដ្ឋអាមេរិក ឬអ្នកដែលបានលាឈប់បំរើក្នុងជួរកងទ័ពដោយត្រឹមត្រូវតាមច្បាប់។ ឯប្តី ឬប្រពន្ធ ឬកូនរបស់អ្នកនោះក៏អាចទទួលលុយ SSI បានដែរ។ អ្នកដែលបានអនុញ្ញាតិ ឲ្យចូលមករស់នៅក្នុងសហរដ្ឋអាមេរិកជាជនភៀសខ្លួននិងអ្នកដែលបានទទួលការអនុញ្ញាតិឲ្យចូលមកជ្រកកោនស្របតាមច្បាប់របស់ក្រសួងអន្តោប្រវេសន៍ (Section 207 &208) និងអ្នកដែលត្រូវរដ្ឋបំបរបង់ឲ្យចេញពីស្រុកនេះ (Deportation) ប៉ុន្តែពេលវេលាបានត្រូវផ្អាកវិញ តាមច្បាប់អន្តោប្រវេសន៍ Section 243 (h) នឹងប្រហែល ជាអាចទទួលលុយ S S I បានហូរហែរហូតអស់ពេល៥ឆ្នាំ ដោយគិតតាំងពីថ្ងៃដែលចូលមកសហរដ្ឋអាមេរិកនេះ (Admission date) និងថ្ងៃដែលបានកំណត់ឲ្យផ្អាកមិនទាន់ឲ្យចេញពីប្រទេស។

ការិយាល័យ Social Secutity នៅក្នុងតំបន់អ្នកនឹងអាចប្រាប់អ្នកថា តើអ្នកអាចទទួលលុយ SSI បាន ឬពុំបាន។

បើអ្នកដាក់ពាក្យសុំលុយ S S I សាជាថ្មី អ្នកត្រូវបង្ហាញឯកសារ ដែលបញ្ជាក់ពីឋានៈ (Status) រស់នៅរបស់អ្នកក្នុងសហរដ្ឋអាមេរិក។ ឯកសារទាំងនោះគឺ

- សំបុត្រកំណើតដែលកើតនៅក្នុងសហរដ្ឋអាមេរិក (US Birth Certificate)។
- ឯកសារដែលបញ្ជាក់ប្រាប់ពីឋានៈរស់នៅក្នុងសហរដ្ឋអាមេរិក ដែលពុំមានសញ្ជាតិជាអាមេរិកាំង ដូចជា Form I-94 ឬ I-551 ពីក្រសួងអន្តោប្រវេសន៍ដែលមិនទាន់ហួសកំណត់ពេលវេលា ឬសំបុត្រស្នាមដែលបញ្ជាក់ប្រាប់ពីការលាឈប់បំរើក្នុងកងទ័ពសហរដ្ឋអាមេរិកនេះ។

**តើប្រាក់ S S I របស់អ្នក និងត្រូវបញ្ឈប់ពេលណា?**

ចំពោះអ្នកដែលមិនមានសញ្ជាតិជាអាមេរិកាំងហើយបានទទួលលុយ S S I មកទល់នឹងថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៦ ច្បាប់ថ្មីនេះបានតម្រូវថា យើង S S A នឹងសើរើពិនិត្យសំណុំរឿងរបស់អ្នកនោះក្នុងកំឡុងពេល១២ខែ ដើម្បីពិចារណាថាតើ អ្នកអាចទទួលលុយ S S I បានតទៅទៀតដែរឬទេ បើតាមច្បាប់ថ្មីក្រោយនេះ។ ក្នុងកំឡុងខែកុម្ភៈ និង មិនាឆ្នាំ១៩៩៧នេះ យើងនឹងផ្ញើលិខិតទៅប្រាប់អ្នកនោះ អំពីរឿងច្បាប់ថ្មី បានតម្រូវឲ្យធ្វើ ដើម្បីអាចបានទទួលលុយបន្តរទៅទៀត។ បើអ្នកនោះមិនអាចធ្វើតាមច្បាប់ថ្មីតម្រូវឲ្យទេ ប្រាក់ S S I របស់អ្នកនោះនឹងត្រូវបញ្ឈប់លែងឲ្យតទៅទៀត ដោយយើងនឹងផ្ញើសំបុត្រទី២ទៅប្រាប់អំពីពេលវេលាដែលត្រូវបញ្ឈប់។

បើអ្នកបានទទួលប្រាក់ S S I តាមច្បាប់ តម្រូវឲ្យសម្រាប់តែ៥ឆ្នាំនោះ យើងនឹងផ្ញើសំបុត្រទៅប្រាប់អ្នកអំពីលុយ S S I រយៈពេល៥ឆ្នាំ និងត្រូវបញ្ឈប់នៅថ្ងៃ-ខែ-ឆ្នាំណា? ហើយសំបុត្រទៅប្រាប់អ្នកថាលុយ S S I ត្រូវបានបញ្ឈប់ជាស្ថាពរ។

នៅពេលណាដែលយើងផ្ញើសំបុត្រទៅប្រាប់អ្នក អំពីប្រាក់ S S I ត្រូវចប់នោះ យើងនឹងពន្យល់អ្នកអំ ពីរបៀបតវ៉ា ដើម្បីបានប្រាក់នោះទៀតហើយនិង ប្រាប់ពីដំណើរការទទួលប្រាក់ S S I ក្នុងពេលដែលកំពុងតវ៉ានោះ។

**ចងចាំអំពី Medicaid !**

បើអ្នកទទួល Medicaid តាមរយៈការទទួលលុយ S S I នោះ អ្នកនឹងអាចមាន Medicaid ដរាបណាអ្នកនៅតែបានទទួលលុយ S S I ។ បើអ្នកមិន អាចទទួលលុយ S S I បានតទៅទៀតទេ Medicaid នឹងមានការប្រែប្រួលទៅតាមនោះ ដែលយើង S S A នឹងប្រាប់នៅក្នុងសំបុត្រដែលផ្ញើទៅនោះ។

បើប្រាក់ S S I ត្រូវបញ្ឈប់ ពីព្រោះអ្នកមិនមានសញ្ជាតិអាមេរិកាំងនោះ អ្នកអាចដាក់ពាក្យសុំបន្តរទៅទៀតបាន នៅពេលណាដែលអ្នក មាន

តទៅទំព័រទី ៦

តមកពីទំព័រទី ៥

សញ្ជាតិជាអាមេរិកាំង ឬមានការផ្លាស់ប្តូរ Status ឬមានគ្រប់ 40QCs (តាមរយៈប្តី ឬប្រពន្ធ ឬឪពុកម្តាយ)។ យើងត្រូវការឃើញក្រដាសស្នាមរបស់អ្នកនោះទាំងអស់។

**ចង់មានបន្ថែមពីប្រាក់ SSI**

អ្នកអាចទទួលព័ត៌មានបន្ថែមទៀត យ៉ាងក្បោះក្បាយអំពីប្រាក់SSI នេះដោយទូរស័ព្ទទៅលេខឥតអស់លុយរយៈពេល២៤ម៉ោងក្នុងមួយថ្ងៃ។ បើអ្នកចង់និយាយផ្ទាល់ជាមួយតំណាង SSA យើងសូមទូរស័ព្ទក្នុងកំឡុងពេល ពីម៉ោង៧ព្រឹកដល់ម៉ោង៧ល្ងាច ចាប់ពីថ្ងៃច័ន្ទ រហូតដល់ថ្ងៃសុក្រ។ ខ្សែទូរស័ព្ទរបស់យើងរវល់ជាងគេ គឺនៅដើមសប្តាហ៍ និងដើមខែ បើយកល្អសូមទូរស័ព្ទខុសពីពេលនេះ។ សូមយកលេខ Social Security របស់អ្នកកាន់នៅក្នុងដៃនៅពេលទូរស័ព្ទនោះ។ អ្នកតំណាងរបស់យើងនឹងអាចប្រាប់អាស័យដ្ឋាន និងលេខទូរស័ព្ទរបស់ Social Security Office ដែលមាននៅក្នុងតំបន់អ្នក នេះបើអ្នកចង់សួរទៅកន្លែងនោះ។

បើអ្នកមានទូរស័ព្ទប្រើដោយចុចនឹងដៃ (Touch-tonephone)អ្នកអាចទទួលព័ត៌មានផ្សេងៗតាមម៉ាស៊ីនថតសំឡេងរយៈពេល២៤ម៉ោងក្នុងមួយថ្ងៃ នេះរាប់ទាំងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យផង។ ចំពោះមនុស្សថ្លង់ អាចហៅតាមលេខ TTY ឥតអស់លុយ1-800-325-0778 រយៈពេលពីម៉ោង៧ព្រឹករហូតដល់ម៉ោង៧ល្ងាច ក្នុងថ្ងៃច័ន្ទរហូតដល់ថ្ងៃសុក្រ។ ក្រសួង SSA (Social Security Administration) មានក្រិត្យក្រមក្នុងការថែរក្សាការសម្ងាត់គ្រប់រឿងរ៉ាវទាំងអស់របស់អ្នកដែលបានទូរស័ព្ទតាមលេខមិនអស់លុយ និងតាមទូរស័ព្ទនៃការិយាល័យនិមួយៗ។ អាស្រ័យហេតុនេះហើយ ទើបយើងមានអ្នកត្រួតពិនិត្យទូរស័ព្ទបន្ថែមពីការទូរស័ព្ទចេញចូលនោះទៀត។

**បើអ្នកមានមនុស្សធានា (Sponsor)**

អ្នកដែលចុះហត្ថលេខាលើក្រដាសសន្យាថាជួយចិញ្ចឹមអ្នក (Affidavit of Support) នៅពេលអ្នកមករស់នៅក្នុងសហរដ្ឋអាមេរិកនោះហៅថា Sponsor របស់អ្នក។ ប្រាក់ខែឬទ្រព្យសម្បត្តិអ្វីៗដែលអ្នកធានាទាំងប៉ុន្មាន (ទោះជារបស់ប្តីឬប្រពន្ធក៏ដោយ គឺយកមកគិតគួរជាប្រាក់របស់អ្នក ឬទ្រព្យរបស់អ្នក ក្នុងកំឡុងពេលដែលមនុស្សនោះត្រូវចិញ្ចឹមអ្នក គិតតាំងពីថ្ងៃអ្នកចូលមកនៅក្នុង សហរដ្ឋអាមេរិក។ ក្រសួង SSA ក្នុងតំបន់របស់អ្នកនឹងផ្តល់ព័ត៌មានដល់អ្នកយ៉ាងច្បាស់លាស់ នៅពេលដែលអ្នកចូលមកសុំលុយ SSI ។

**ដើម្បីចូលសញ្ជាតិអាមេរិកាំង**

**(Naturalization)**

អ្នកអាចទទួលព័ត៌មានដើម្បីចូលជាសញ្ជាតិអាមេរិកាំង ដោយសរសេរសំបុត្រទៅសាកសួរ ឬទៅដល់ទីកន្លែងក្រសួងអន្តោប្រវេសន៍ (INS) ឬក៏ទូរស័ព្ទតាមលេខឥតអស់លុយ 1-800-870-3676 ដើម្បីសុំសំបុត្រដាក់ពាក្យសុំចូលសញ្ជាតិ N-400 FORM ។

ប្រែសម្រួលដោយ ទូច ស៊ីគី

CONWAY
INSURANCE AGENCY

ក្រុមហ៊ុនធានារ៉ាប់រង ខនវេ

**Philip Sopheap Muth**
**Representative**

Po.Box 1744
77 E. Merrimack Street
Lowell, MA 01853

**508- 454-5054**

# ចេះតែល—!!

**Vuthy Vann**



* ធ្វើសាលារៀនសំរាប់ក្មេង ល្អជាងធ្វើគុក សំរាប់មនុស្សចាស់។

›✪✪✪✪✪✪✪✪✪✪‹

* សឹករិចបន្តិចម្តងៗ ប្រសើរជាងមានច្រែះស្នឹមកើតឡើង។

›✪✪✪✪✪✪✪✪✪✪‹

* សុខចិត្តស្តួច តែកុំឱ្យដាច់។

›✪✪✪✪✪✪✪✪✪✪‹

* បើអ្នកធ្វើឱ្យមនុស្ស គិតដូចគំនិតគេកំពុងគិត គេនឹងស្រឡាញ់អ្នក តែបើអ្នកធ្វើឱ្យគេគិត តាមសេចក្តីពិត។ គេនឹងស្អប់អ្នក។

›✪✪✪✪✪✪✪✪✪✪‹

* អ្នកដែលឃុំគ្រងសេចក្តីស្រេកឃ្លានខ្លួនឯងបាន រមែងឃុំគ្រងសុខភាពខ្លួនឯងបាន។

›✪✪✪✪✪✪✪✪✪✪‹

* មិនបានទទួលការប្រៀនប្រដៅ ប្រសើរជាងទទួលការប្រៀនប្រដៅថោកទាប។

›✪✪✪✪✪✪✪✪✪✪‹

* គប្បីធ្វើខ្លួនជាបុគ្គលដែលគេប្រដៅបានដោយងាយ។

›✪✪✪✪✪✪✪✪✪✪‹

* ប្រដៅអ្នកដទៃយ៉ាងណា គប្បីប្រដៅខ្លួនឯងយ៉ាងនោះដែរ។

›✪✪✪✪✪✪✪✪✪✪‹

* បុគ្គលដែលស្គាល់ខ្លួនឯងដោយច្បាស់លាស់ រមែងរាប់អានខ្លួនឯងយ៉ាងតិចបំផុត។

›✪✪✪✪✪✪✪✪✪✪‹

* ទោះបីជាគេអានសៀវភៅរាប់ម៉ឺនក្បាលដែលគ្មានការចងចាំ មិនប្រសើរជាងការទន្ទេញពាក្យមួយឃ្លា ដែលមានខ្លឹមសារសំរាប់ជីវិតគេដែរ។

›✪✪✪✪✪✪✪✪✪✪‹

* មនុស្សមានពេលតែម្តងគត់សំរាប់រស់ តែគេមានពេលច្រើនផងណាស់សំរាប់ស្លាប់។

›✪✪✪✪✪✪✪✪✪✪‹

* ជួនកាលដើម្បីបំបាត់សំឡេងខ្លាំងមួយ គេត្រូវបើកសំឡេងមួយទៀតដែលខ្លាំងជាងសំឡេងមុន។

›✪✪✪✪✪✪✪✪✪✪‹

* មនុស្សដែលមិនមានកំហុស គឺមនុស្សដែលមិនមានធ្វើការអ្វីសោះ។

›✪✪✪✪✪✪✪✪✪✪‹

* ប៉ោតទទេញស្ងួរខ្លាំងជាងប៉ោតដែលមានទឹក។

›✪✪✪✪✪✪✪✪✪✪‹

* ជំលោកជាថ្នាំរក្សារោគ។

›✪✪✪✪✪✪✪✪✪✪‹

* ជាមនុស្សស្លាប់ ល្អជាងជាមនុស្សស្ងួម។

›✪✪✪✪✪✪✪✪✪✪‹

* យល់ព្រមអោយខុស ងាយជាងកែខៃឱ្យត្រូវ។

›✪✪✪✪✪✪✪✪✪✪‹

* ឈ្នះខ្លួនឯង ល្អជាងឈ្នះអ្នកដទៃ។

›✪✪✪✪✪✪✪✪✪✪‹

* ដាស់តឿនខ្លួនឯង ល្អជាងដាស់តឿនអ្នកដទៃ។

## បញ្ហាសង្គម ?...

បញ្ហាក្នុងសង្គមមានច្រើនលើសលប់ចំពោះយើងដែលជាជនជាតិភាគតិចដែលមករស់នៅស្រុកគេនេះ។

សូមកុំយល់ច្រឡំឲ្យសោះថា: ខ្លួនយើងគ្មានបញ្ហា ហើយថាសង្គមមានបញ្ហា។

សូមកុំយល់ច្រឡំឲ្យសោះថា សង្គមនេះធ្វើឲ្យយើងមានបញ្ហា ហើយបើចង់ដោះស្រាយបញ្ហានេះទាល់តែសង្គមថ្មីហ្នឹងផ្លាស់ប្តូរ ទើបលែងមានបញ្ហា។

ចូរចងចាំថា សង្គមគេនេះមានអាយុយូរអង្វែង មុនពេលដែលយើងបានឈានជើងមករស់នៅ បង្កើតជាកូនពូនជាចៅទៅទៀត ហើយការជឿនលឿនក៏វិវត្តន៍ទៅយ៉ាងអស្ចារ្យបំផុត។ ទោះជាមានមនុស្សខ្លះធ្វើខុសខ្វចយ៉ាងណាក្តី ក៏វាជាភាគតិចបំផុត បើប្រៀបធៀបទៅនឹងការជឿនលឿននិងចំរុងចំរើននៃសង្គមនេះ។

សូមបញ្ជាក់ថា នេះមិនមែនជាការបន្ទោសដល់អស់លោកដែលខំថែរក្សារទុកនូវប្រពៃណីយ៍ខ្មែរយើងដ៏មានតម្លៃ ដែលជាតំណាងរបស់ខ្មែរពិតៗនោះទេ។ ប៉ុន្តែដើម្បីកសាងជីវភាពថ្មីឲ្យមានការជឿនលឿនទាន់នឹងការវិវត្តិន៍ នៃសង្គមថ្មីនេះ យើងត្រូវតែផ្លាស់ប្តូរ......! យើងត្រូវតែរៀនទទួលយកនូវចំណេះវិជ្ជាថ្មីបន្ថែម។ មិនមែនមានន័យថា បំភ្លេចខ្លួនយើងជាអ្នកណានោះទេ។

**ពាក្យចាស់លោកថា:**

*"ចូលស្ទឹងតាមបទ ចូលស្រុកតាមប្រទេស"*

សាន សាម៉ុន

# Cambodian Women Speak: an interview with Sara Im and Chantha Bin.

Cath pierSath and Joachim Nickerson



Sara Im, a rather *reserved and soft spoken but articulate* woman, came out of the Thai-Cambodian border Khao-I-Dang Refugee Camp. She arrived in the United States September 1981. She initially lived in Connecticut and moved to Lowell after a few years there. She came to the U.S. by herself, and later brought her mother and three brothers to this country. She has a college degree in Mathematics and Business Management. Now, she is working with the Cambodian American League of Lowell (CALL) as its program coordinator. The C.A.L.L. is an organization that focuses on economic development in the Southeast Asian community in Lowell. They provide small business training, help people understand how to acquire loans to achieve their dream of buying a home and become literate in the business world.

Sara is one Cambodian women who has achieved success. When asked to define "success" she spoke of having a balance in various areas of life. This includes a family, a stable job for financial security and a moral and spiritual responsibility towards the community in which you live. To achieve success, she also adds, one has to be very self-determined and have a desire to learn and grow. One must want to make a difference not only in one's own life, but in the lives of other people and be able to see oneself as a contributing member of society. Importantly, one must do what one loves in order to achieve a certain self-sufficiency and satisfaction.

In society, some social, economic and political issues are unique only to women. They have to balance family and work and also their roles in society. A lot of the issues are difficult, and Sara has identified several relating to her own life. Being a woman and an immigrant in this country has expanded her horizons and perspective, but not without struggles. She had to deal with cultural and language barriers, which many Cambodian women are still struggling with today. Many Cambodian women in America are not as integrated into the mainstream American culture as Sara has. A lot of the Cambodian women in Lowell are experiencing post traumatic stress from the war and the Khmer Rouge years. They have not recuperated like Sara and thus it is harder for them to provide their children with any positive wisdom to guide them. Therefore, it is more difficult for them to identify and achieve their own personal goals. Although Sara is fluent in English and Khmer, she still feels that it is more challenging to realize her goals than it would for a native English speaker.

Sara has always been a very good role model for young women. Her commitment to the community and her long term involvement demonstrate her ability to face challenges. Every year she assists CALL in organizing a beauty pageant which focuses on helping young women build self-esteem and establish roots and cultural identity. It helps young women identify and realize personal goals in addition to strengthening the family.

Sara is also participating in the Lowell Career Beginning Planning Team to provide youth with mentors who could assist them in clarifying their future career and goals. When asked what advice she would give to young women, she said they should identify a role model or mentor who they like, and follow his or her example in order to achieve their own success. Success includes the motivation to learn, grow and experience new challenges.

Sara is always looking for learning opportunities. Recently, she completed an Economic Development Leadership Training provided by CIRCLE (Center for Immigrant, Refugee Community Leadership Empowerment).

When asked, with her knowledge and skill, if she wants to go back to Cambodia to help, she said that she doesn't have enough strength to go there and work. However, she will visit family. Her mission is to help people here in the United States since there is a great need especially among the Cambodian people. "Cambodians abroad must be strong and unified if they want to help rebuild Cambodia from its war torn history," she said.

While a lot of Cambodian men occupy themselves with the politics of Cambodia, Sara keeps herself

Continue to page 10

# New England Rehabilitation, Inc.

*Physical Therapy services*

មន្ទីរពេទ្យដែលខ្មែរនិយម ដោយមានអ្នកជំនួយខ្មែរ

ជួយសម្រួលការគ្រប់ពេលវេលា

**មានវេជ្ជបណ្ឌិតចំណានៗ**

**ក្នុងការព្យាបាលជម្ងឺគ្រាំគ្រាបណ្ដាលមកពី**

**គ្រោះថ្នាក់ចរាចរ រថយន្ត យានយន្តក្នុងរោងចក្រ**

**រអិលដួលជាដើម!**

**77 East Merrimack St.,**
**Suite 22**
**Lowell, MA 01852**

**Tel (508) 452-4156**
**Fax (508) 452-0317**

Continue from page 8

informed without getting involved in the political quagmire. She is an American citizen, and she is well informed about political issues both in America and in Cambodia. She votes in every election.

Sara reflected on the role older Cambodian women play. She thinks of her mother who had little education, but who helped her become strong and determined as an individual. Her mother has been a positive role model by being a good example. Sara appreciates her mother's wisdom and simplicity in her ways of resolving life's day to day problems. Her mother draws the daily wisdom of life from her own experience. In many ways, Sara appreciates the older people because of their life experiences. "Older people - a lot of them are wise," she said.

Sara talked about intergenerational relationships. She feels that teenagers who grow up in America have a harder time dealing with cross-cultural issues. They have to figure out where they belong and where they are in American society. "It is very hard for them to balance two different cultures." The younger generation is the future of the Cambodian American community. The obstacles they are facing now don't necessarily weaken them, but probably will strengthen them since they have gone through the struggles and appreciate what they have been through. "I have to keep reminding myself all the time about where I came from and how I survived the Khmer Rouge."

As adults, we have to be positive role models and provide them with guidance and support to face the challenges they deal with in life and prepare them for the future. One does not have to have a college degree to be a positive role model. "My mother never had a college education, but she teaches me ways to save money, life management skills and provides me with practical solutions to solve conflicts."

The Cambodian community in Lowell has suffered a great deal from a bad reputation due to gang violence and intergenerational conflicts which evolves from a lack of basic skills to identify and resolve issues. "This is why we need to work extra, extra hard to recuperate from this gang image."

Sara, in her integrity, looks at life in a practical sense just as her mother taught her. This includes basic skills to deal with day to day living and problem solving. As a positive role model, this is what she would like to give to other young women.

## Chantha Bin and Her Journey



At the age of nine, Chantha Bin was separated from her family by the Khmer Rouge and put into a children's camp. The war created many orphans due to land mines, starvation, relocation and mass killing. When the Vietnamese occupied Cambodia in 1979 she fled with other people and was befriended by an old lady who she called "grandmother". They both became very ill and were in comas and the old woman's family dug two graves. At this point she had a dream of a man in white who said there is room for only one. They had to make the choice as to which one stayed. The old woman had trouble making a decision and the man suggested that she go because she was old and had lived her life whereas Chantha was young and had a lot of years ahead of her. She awoke, the old woman had been buried and the family was ready to put Chantha in the grave as well.

Chantha came to the United States in 1982 as an unaccompanied minor and lived in Amherst MA. with American foster parents. Cambodian and other unaccompanied refugee minors were sponsored by Lutheran Child and Family Services who recruited foster homes. She had two years of education in a refugee camp, Sakeo I and II, before coming to America. Her foster father was a professor at the University of Massachusetts, Amherst; her foster mother was a secretary. When asked why she had succeeded when others hadn't, she said that she had support from other minors who were mostly male but who supported and encouraged her and did not see her as a sex object. She lived in a very disciplined environment with her foster parents which was similar to how Cambodian parents raise their children. She finished high school and went to college. While in college

Continue to page 12

# ការិយាល័យច្បាប់

**VANTHAN R. UN**
**ATTORNEY AND COUNSELOR AT LAW**

## មេធាវី អ៊ុន វ៉ាន់ថន

ការិយាល័យយើងខ្ញុំជាការិយាល័យច្បាប់តែមួយគត់ក្នុងរដ្ឋម៉ាសាឈូសែត ដែលមានមេធាវី ជាជនជាតិខ្មែរមានការប៉ិនប្រសប់ និងវៃឆ្លាតក្នុងការកាត់ក្តី។ លោកអ្នកអាចទទួលការពន្យល់ណែនាំនូវបញ្ហាច្បាប់ផ្សេងៗយ៉ាងស្ទាត់ជំនាញជា ភាសាខ្មែរដោយផ្ទាល់។

- គ្រោះថ្នាក់ចរាចរណ៍ ⇨ **AUTO ACCIDENT**
- គ្រោះថ្នាក់កន្លែងធ្វើការ ⇨ **WORKMAN'S COMPENSATION**
- ច្បាប់ពាណិជ្ជកម្ម ⇨ **BUSINESS LAW**
- ច្បាប់អន្តោប្រវេសន៍ ( ធានាបងប្អូន) ⇨ **IMMIGRATION**
- ធនក្ស័យ ( បែងក្រ័បស៊ី) ⇨ **BANKRUPTCY**
- បញ្ឈប់កុំអោយគេរឹបអូសផ្ទះតាមផ្លូវច្បាប់ ⇨ **STOP FORECLOSURE**
- គ្រោះថ្នាក់ដោយជាតិសំណពុល ⇨ **LEAD PAINT POISONING**
- កាត់ឈ្មោះផ្ទះ ⇨ **CLOSING**
- ចែកកេរ្តិ៍ មរតក ⇨ **WILLS & TRUST**
- សម្រុះសម្រួលជម្លោះប្តីប្រពន្ធ ⇨ **DIVORCE MEDIATION**
- ច្បាប់ឧក្រិដ្ឋកម្ម ⇨ **CRIMINAL LAW**

**16 PINE STREET ( Suite 8), LOWELL, MA 01851**
**OFFICE (508) 937-2201, HOME (508) 458-7738**
**FAX (508) 937-2204**

Continue from page 10

she began to experience post-traumatic stress disorder syndrome and lost a great deal of weight; she was only 79 pounds. Her foster mother took her to various doctors who were unable to diagnose the problem. She failed college and was expelled because her grade point average fell.

At this point Chantha got a job helping special needs children, and it turned her life around. She began to work with a child who she calls Benjamin who had cerebral palsy, and he didn't like to be touched or fed. This boy was unable to feed himself and do other basic skills such as going to the bathroom. He was unable to take care of himself and through working with Benjamin and others, she began to look at her own life. She realized that she had abilities which these children didn't and she began to ask herself why she was so sad. She began to see her abilities in a positive way. She became proactive, and one day her relationship with this boy changed her life. She decided to hug him and tell him that she was there for him. Initially she communicated with him by singing. It took time, but he did come around and began to feed himself and allowed her to become emotionally close to him.

Chantha was transformed by the experience of Benjamin and was able to go back to college and graduate with a degree in early childhood development. She had to get beyond her own suffering to reach somebody else and then both people grow.

Two years ago she went back to Cambodia where she met her biological parents after almost twenty years of separation. Her mother was quite emotional, hugged her and cried, but she says that she didn't have the same emotion because she didn't know her parents. She realized that a mother's love for her child is always with her, always wondering where the child is, but the child can forget if the child doesn't have any memory of the mother. The mother can't forget.

She had difficulty relating to her mother in an emotional way from another perspective as well: she had a negative impression of her country of origin and culture because of its recent history and genocide. There was war and destruction and throughout her childhood she experienced nothing but loss and separation from loved ones. She ran from war, was alone and vulnerable. A symbol of hope and healing was present when she visited Angkor Wat and saw the beautiful sculptures smiling at her, and she began to realize that she belonged to a heritage of a great civilization than she had thought. The expression of the base relief revealed to her that she was a part of an ancestry that was gentle rather than cruel and charming rather than harsh and she began to feel proud and relieved of self-condemnation and shame.

At the moment Chantha is working with the school system as a community Liaison with parents, and she hears the concerns of parents. It is her impression that the women take the greater responsibility in raising children and caring for the home. The men sometimes abandon the family. Some of the women raise their children alone and have few emotional supports. Like Sara Im, she believes that Cambodian women should form a coalition as a support system, a self help group.

As a facilitator in the school system she has the opportunity to assist with communication between parents and children. While she isn't a trained counselor, she believes that she helps with the healing process as well. By being open, honest and down to earth with the parents she found that they trust and appreciate her. Through working with the community and talking with people we are all in the same circle of suffering even though our specific issues may vary.

Continue from page 4

will be back in the office the very next day to wait to see where they will sleep that night. This is totally unfair to any child, but this is reality. We just do not have the number of foster homes we need to accommodate all the children that come into care. We will find a home each night for a child in need, the home may only be temporary, but at least the child will be safe.

The Department, statewide is trying to open 1,000 new foster homes, throughout the entire state, within the next year. The Lowell office has a target number of 48 new foster homes. We do not ask people to have a large home or to take large numbers of children into their homes. If you have room for one child, this is fine with us. We want applicants to consider how a foster child will fit in with their own families. How many foster children can fit in with your family, what age child would be a good match for your family. Foster families receive the professional support from the staff at DSS. Foster parents are monetarily reimbursed

Continue to page 22

# មណ្ឌលសុខភាពសហគមន៍ឡូវែល

## Lowell Community Health Center

## Administration Office

**585 Merrimack Street • Lowell, MA 01854**

**☎ (508) 937- 6045 FAX (508) 970 - 0057**

**មណ្ឌលប្រចាំសហគមន៍ ផ្តល់ការថែរក្សាសុខភាពដល់ប្រជាជនគ្រប់អាយុ នៅក្នុងតំបន់ឡូវែល**
**មានបុគ្គលិកនិយាយភាសាខ្មែរនៅគ្រប់វិជ្ជាពេទ្យ២**

**ពេលម៉ោងធ្វើការ** ពីថ្ងៃ ច័ន្ទ ដល់ថ្ងៃ សុក្រ វេលាម៉ោង ៨:៣០ព្រឹក ដល់ម៉ោង ៥:០០ល្ងាច មានបើកពិនិត្យសុខភាពមនុស្សចាស់ និងមនុស្សពេញវ័យ ពេលព្រឹកព្រលឹម និង ថ្ងៃល្ងាច។
(ការពិនិត្យសុខភាពមនុស្សចាស់មិនចាំបាច់មានការណាត់ទុកជាមុនឡើយ)។

**តម្លៃពិនិត្យ** សឹងតែគ្រប់ផ្នែកពិនិត្យជម្ងឺទាំងអស់នៅមណ្ឌលសុខភាពយើង មានទទួលការធានារ៉ាប់រងសុខភាពពី NEIGHBORHOOD HEALTH PLAN, MEDICAID និង MEDICARE បើលោកអ្នកគ្មានការធានារ៉ាប់រងផ្នែកសុខភាពទេនោះ ឬក៏មិនមានការធានារ៉ាប់រងគ្រប់គ្រាន់មណ្ឌលសុខភាពយើងអាចមានការបន្ធូរថ្លៃពិនិត្យទៅតាមទំហំគ្រួសារ និងប្រាក់ចំណូល។

**ដើម្បីអោយមានឈ្មោះ ជាអ្នកជម្ងឺនៅមណ្ឌលសុខភាពសហគមន៍ឡូវែល**
ដើម្បីទទួលការព្យាបាលជម្ងឺនៅមណ្ឌលសុខភាពយើង ជាដំបូងលោកអ្នកត្រូវចុះឈ្មោះជាមុន ដោយទូរស័ព្ទមកលេខ **937-6100** ឬអញ្ជើញមកទីមណ្ឌលសុខភាពតែម្តង

# MTV's Hip Hop Black Culture and Cambodian Youth

*Chath pierSath*

The hip hop culture, which is often viewed as black culture, has found its way to the hearts of Cambodian youth. In raps, these Cambodian youth, gangsta wannabes are finding a new sense of self in black street life - as portrayed in rap music. Rap is the sermon of the street and youth against conventionality and cultural restriction.

Beyond the boundaries and restrictions of their own culture, Cambodian youth who grow up in America are moving fluidly between other cultures, borrowing from whoever they can relate to. Often times, what they borrow is seldom viewed as something good. What they do and express in their lifestyle, a lot of the time, raise eye brows and questions about who they are and what they are all about. Parents, in particular, are scared and skeptical about the whole thing, when they hear their children listen to rap music and see them wearing baggy clothes. Some boys even pierced their ears, which their fathers would never do since gender roles are tightly defined within their cultural context. Here, in America, anything goes. Everybody is free to do whatever he or she wishes. Individual freedom is loudly being expressed and valued.

Cambodian parents who are less integrated into the American cultural mainstream are lost. Some can't understand why their children have chosen to listen to this obnoxious, loud and in-your face form of music and wear such unattractive baggy clothes, hang out on the street and dance as though they are pointing fingers at each other, trying to pick a fight. What they are doing is actually their way of rebelling against their parents and any notion of cultural establishment. The in-your face lyrics that they gyrate to give them an identity, a way of relating to the world and their peers. These in-your face lyrics often describe and sometimes glorify violence, misogyny, fast living, drinking and drugging. Some lyrics are just senseless, repetition of screams and "I do you good baby," most of which you don't understand.

Parents are not so much to blame for all of this. MTV and other medians of cultural infiltration and media are constantly telling these youth how to behave, act and dress. Wearing a baseball cap sideways is cool and it signifies a certain sign of group identity. Baggy jeans and cloddy athletic shoes are trendy. The music video stars are wearing them. The girls soaked their lips mud red. They project their figures by wearing bell bottom pants and tight shirts brought back from the 60s. They dance slow dances with boys before they even married. Young girls as young as twelve are learning the arts of flirting.

Some parents are overwhelmed, fearful and afraid of what their children are turning into. They think their children are cultural monsters who are experiencing some cultural difficulties, trying to figure out where they belong, what they believe and why they are put on this earth, and for what purpose. Maybe they're just expressing the spirit of being young in this free for all nation, America.

One night, at a non-smoking and non-alcohol fundraising party that the CMAA peer leaders put on at Roger School, I saw several young boys as young as twelve smoking Marlboro cigarettes. There were a lot of them there. They paid five dollars to get in. Those who smoked weren't allowed to take their cigarettes and lighters in. At the beginning, a few danced, and even toward the end, only half of those who were there danced. The rest sat and watched. That was their night out of the house. Those who danced pumped their arms front to back. Their legs stayed in rhythm, propelling their short wiry frame forward almost airborne. This boy and his gang danced as if they were swimming through time. Easy. Smooth. Cool. Some of them wore a bandanna over their heads. A young man had a nose ring and one of his pant legs rolled up which doesn't make sense to me. They looked nothing like the innocent, charming, Angkorian faced Khmer children I know, and if I was in their parents' shoes, I would probably be very shocked to discover what I had seen. At the same time, how everyone can not judge by external appearances because there can be gentle spirits beneath the facade. I understand them because I also grew up in this country and realize the issue of trying to balance two cultures is harder for these young people.

**Continue to page 15**

# វិបត្តិចំពោះក្មេងដែលបណ្តាលមក ពីការឈ្លោះវាយតប់ក្នុងគ្រួសារ

ក្នុងការសិក្សាស្រាវជ្រាវជាច្រើនដែលមានគោលដៅក្នុងការស្វែងរកនៅទ្រឹស្តី ចំពោះក្មេងទាំងឡាយដែលបានឃើញឪពុក និងម្តាយរបស់គេ ធ្វើអំពើឃោរឃៅក្នុងគ្រួសារ ដូចជាឈ្លោះវាយតប់គ្នាជាដើម។ល។

ក្មេងនោះនឹងធ្វើត្រាប់ទៅតាមឪពុកម្តាយ ដូចជាឪពុកម្តាយរបស់គេ បានធ្វើនៅអំពើទាំងនោះដូច្នោះដែរ។ ហើយក្មេងទាំងនោះនឹងក្លាយទៅជាអ្នកធ្វើទុក្ខទោសគេ ឬក៏ក្លាយខ្លួនជាអ្នករងគ្រោះ ដូចមនុស្សពេញវ័យដែរ។

- ដូច្នេះភស្តុតាងនៃការឈ្លោះវាយធ្វើបាបគ្នាក្នុងគ្រួសារបានបញ្ជាក់អោយឃើញថាជាការប្រព្រឹត្តនៅបទល្មើសនិងការប្រព្រឹត្តអំពើឃោរឃៅចំពោះក្មេង។

- ក្នុងការស្រាវជ្រាវមួយនៅរដ្ឋម៉ាសាឈូសេតបានបង្ហាញអោយឃើញថាក្មេងដែលកើតមកពីផ្ទះគ្រួសារដែលធ្វើអំពើឃោរឃៅក្នុងគ្រួសារ ក្មេងនោះប្រព្រឹត្តអំពើឃោរឃៅឧក្រិដ្ឋកម្ម ចាប់រំលោភគេ២៤ដងច្រើនជាងក្មេងដែលកើតពីផ្ទះគ្រួសារណា ដែលមិនមានធ្វើអំពើឃោរឃៅក្នុងគ្រួសារ។ មានចំនួន៧៤ភាគរយនៃក្មេង ទាំងនេះប្រព្រឹត្តអំពើឧក្រិដ្ឋប្រឆាំងនិងក្មេងដទៃទៀត។ និងមានចំនួន៥០ភាគរយទៀតនៃ ក្មេងទាំងនេះចូលចិត្តប្រព្រឹត្ត គ្រឿងញៀន ផឹកសុរា និងគ្រឿងស្រវឹងផ្សេងៗ។

- ក្នុងការស្រាវជ្រាវមួយទៀតនៅរដ្ឋ Oregon បានបញ្ជាក់អោយឃើញថា មានក្មេងជំទង់ចំនួន៦៨ភាគរយ ដែលបានធ្វើឲ្យគេខឹងសម្បារគឺជាក្មេងដែលកើតមកពីផ្ទះគ្រួសារ ដែលធ្វើអំពើឃោរឃៅក្នុងគ្រួសារ។

- ក្នុងការស្រាវជ្រាវមួយផ្សេងទៀត បានបញ្ជាក់ឲ្យឃើញថាមានក្មេងប្រុសចំនួន៦៣ភាគរយដែលមានអាយុពី១១-២០ឆ្នាំដែលជាប់នៅក្នុង គុកដោយសារធ្វើឃាតមនុស្សនៅសហរដ្ឋអាមេរិក គឺជាក្មេងដែលសម្លាប់ម្តាយរបស់គេ ដែលធ្វើបាបគេ។

- មានការសិក្សាមួយទៀតនៅពេលថ្មីៗនេះ បានបញ្ជាក់អោយឃើញថា ក្មេងណាដែលឃើញគេវាយធ្វើបាបម្តាយរបស់គេក្មេងនោះ នឹងមានបញ្ហាវិបត្តិខាងផ្លូវចិត្តដូចជាគេវាយ ធ្វើបាបចំពោះខ្លួនវាផ្ទាល់អញ្ចឹងដែរ។ ហើយក្មេងនោះមានបញ្ចេញនៅសញ្ញាឈ្លានពាន-ខូចចិត្ត និងមានបញ្ហាអំពីអកប្បកិរិយាផង ដែរ។

ម្យ៉ាងទៀតក្មេងណាមួយដែលឃើញ ឪពុកវាយធ្វើបាបម្តាយក្មេងនោះភាគច្រើន គឺធ្វើបាបគូរគាប់របស់គេ១១ដងច្រើនជាងក្មេង ដែលកើតមកពីគ្រួសារណាដែលរស់នៅដោយសុភមង្គល។

សេចក្តីរៀបរាប់និងការបកប្រែសម្រួលយ៉ាងសង្ខេប អំពីវិបត្តិចំពោះក្មេងដែលបណ្តាលមកពីការឈ្លោះវាយតប់ក្នុងគ្រួសារសូមស្មេះតែប៉ុណ្ណេះសិន។

សូមលោកអ្នកមេត្តារង់ចាំអានអត្ថបថនេះ នៅលេខក្រោយទៀត។

បើលោកអ្នកមានសំណួរអ្វីអំពីរឿងនេះ សូមទូរស័ព្ទមកខ្ញុំ ភិធ្មើ អឿ ធ្វើការនៅ EMERGE ទូរស័ព្ទលេខ (617) 547-9879 ឬទូរស័ព្ទមកខ្ញុំតាមរយៈសមាគមខ្មែរប្រចាំ ទីក្រុងឡូវែលតាមទូរ ស័ព្ទលេខ:(508) 454-4286 រៀងរាល់ថ្ងៃព្រហស្បតិ៍ ពីម៉ោង ១១:៣០នាទីព្រឹក ដល់ម៉ោង៥ល្ងាច។

សូមអរគុណ

Continue from page 14

This one young man has a very distinguished Khmer face, wide nose and big beautiful lips, but he lives in the wrong century. He got on the floor, break danced, his baggy clothes, long, dyed hairdo pushed him out of the Khmer Empire. He could have been a warrior then, but hip hop had him fully catered and controlled to its rhythm. He chain smoked Marlboros with his friends, talked street English and was totally illiterate in his own culture and language. This is his culture of earrings, nose rings, long, punky dyed hair, pumas shirts, Adidas shoes, large neck chains, Marlboro cigarettes, skin tight shirts, baggy, doggy pants, baseball and ski caps. He feels comfortable in them as we feel comfortable in our "so-called normal clothes." These symbols of hip hop culture is now widely diffused into the hearts of Cambodian youth.



Junior High kids are learning computer at the CMAA.

# FAY McCABE

FUNERAL DIRECTORS

# ផ្ទះដំកល់សព

## FRANK McCABE

105 Moore St.
Lowell, MA 01852
☎(508) 459-9222

**យើងខ្ញុំមានទទួលបំរើដូចតទៅៈ**

❶ រៀបចំបុណ្យបង្សុកូល សូត្រមន្ត តាមប្រពៃណីខ្មែរ នៅនឹងកន្លែង។

❷ សំរួលក្នុងការទិញក្តារ កោដិ និងទីកន្លែងបញ្ចុះសព ឬបូជាសព។

❸ មន្ទីរធ្វើបុណ្យស្អាតបាត ព្រមទាំងមានកន្លែងចតឡានធំទូលាយ។

❹ ទទួលដឹកជញ្ជូនសព ឬធាតុគ្រប់ទីកន្លែង ក្នុងនិងក្រៅប្រទេស។

❺ ទទួលលាបមុខធ្វើមេកអាប់ រៀបចំសពអ្នកដែលចែកឋានទៅ ដោយយកចិត្តទុកដាក់។

❻ មានរៀបចំក្បួនដង្ហែរសពដោយផ្តល់ជូននូវរថយន្តបី ១-សំរាប់ដឹកសព ២-សំរាប់ដឹកផ្កា និងលីម៉ូស៊ីន ៣-សំរាប់ដឹកគ្រួសារ។ល។

# American Tobacco Companies Are Cashing In On Cambodia's Poor

*Chath pierSath*

In Cambodia, there are two landmines for every child and adult. The case of HIV/ AIDS is on the rise. The 70% forest covered land has been reduced to 40% in just three years. Corruption is a way of life among government officials. With an increase in bars and nightclubs comes an increase in HIV/ AIDS cases, alcoholism and domestic violence. To top this, there's the problem of smoking and American Tobacco Companies cashing in on Cambodia's poor.

Newport, Camel and Marlboro cigarettes, which are most favored by young people in the United States, are also very popular among Cambodian youth in Cambodia because they come from America. Marlboro is widely advertised. Groups of Marlboro girls can be seen all over the city streets dressed in Marlboro colors, red and white, giving men free cigarettes.

Most of these girls are high school age students. There are not many jobs for young girls in Cambodia. Beside prostitution, they sell beers and cigarettes and work long hours in restaurants for a very low wage.

"Here, try one," I was once urged by a girl. "It's Marlboro smooth, freshest taste, from America."

There are hundreds of foreign cigarettes in Cambodia. One cannot list them all. There's one brand, "Angkor," which one would think is an indigenous product, but on the label, it says that the tobacco is from the United States of America.

Each company has its own sales pitch. However, everyone of them uses young girls to sell their product. They dress in the colors on the cigarette pack. The beer companies make them wear uniforms that represent the country where the beers come from. Some are dressed like they were in a beauty pageant, wearing evening gowns. They wear sashes such as "Miss Tiger Beer" or "Miss Marlboro."

Cigarette brands like Lucky Strike, Marlboro, Newport, 555 and the French version of Alan Delon take over the airwaves and television ads. They pay beautiful actors to endorse it. "It's smooth and fresh," says one actor as he takes in the smoke and blows it back out of his nostrils as though he's Humphrey Bogart (who by the way died of cancer).

In the United States, while Americans are trying to kick their smoking habits, the Cambodian boys are just starting and doing it the Marlboro way. Boys as young as thirteen are seen smoking with their gangs. I remember attending a CMAA peer leaders' fundraising party one Saturday night, out of the 40 or 50 young men who smoked, all smoked Marlboro, a cigarette with a very high content of carcinogen and chemicals to hook you up.

"According to a recent international report, smoking kills 3 million people every year, and the annual toll could reach 10 million by 2020. So far, most of tobacco's victims have been men in developing countries, but now, the report says, more women in the West and men in developing countries have begun to smoke. However, while Westerners struggle to kick the habit, tobacco companies are casting about for — and finding — new groups of people ready and willing to light up" (from *the World Press Review*, November, 1994, "Smoking Wars").

In Cambodia alone, there's no way of telling how many people would die of lung or heart disease and cancer caused by smoking. Most men don't live that long. The average life expectancy is between 45 and 50 years, and according to a report by the World Health Magazine in 1995, chronic diseases like lung cancer and heart disease are generally uncommon because relatively few people survive to those ages when such diseases become manifest. In Cambodia, health data and figures showing the patterns of tobacco use are poor and unreliable. Yet smoking is particularly risky in Cambodia where populations are anemic because it reduces their blood's oxygen - carrying ability. Very poor people often use tobacco

Continue to page 18

ព្រះវិហារអ៊ីណ្ណាន ប្រេសប៊ីតេរៀន
273 SUMMER STREET LOWELL, MA 01852
(508) 452-7787
កម្មវិធីថ្វាយបង្គំព្រះ ៖ម៉ោង១០:១៥ព្រឹក
គ្រូគង្វាល ដេវិឌ ម៉ាឡូន
សូមអញ្ជើញលោក/លោកស្រីចូលរួមប្រជុំថ្វាយបង្គំព្រះគ្រីស្ទ
ជាមួយយើងខ្ញុំរៀងរាល់សប្តាហ៍ជាភាសាខ្មែរនិងអង់គ្លេស

Continue from page 17

as an appetite suppressant — a cheap and accessible means of warding off hunger pangs. The men who drive cyclo and motortaxis, and street children especially, use cigarette as well as alcohol to suppress their appetite.

A country like Cambodia does not have the financial ability to educate people about the danger of smoking. While health education messages against smoking are widely disseminated in developed countries, they are nowhere to be found in Cambodia. Television, radio and newspaper outreach are impossible since they have all been taken over by tobacco companies who have money to pay for air time.

The international tobacco companies, fearful of declining profits in the West, are turning toward new markets in Cambodia and other Southeast Asian countries. In Laos, during the water festival's boat race, the winner takes Marlboro home: Marlboro money, Marlboro cap and T-shirt, even Marlboro trophy. Marlboro billboards in Cambodia are very visible in every social and traditional event. The handsome, good old American cowboy on the billboard is seen urging people to smoke. What people don't know is that the man in the picture with a cigarette in his mouth died of lung cancer. With controls over nicotine and tar content, health warnings, and advertising a lot less stringent in Cambodia, Marlboro is free to sell and enlarge its billboards.

For a dollar (2500 riels), any Cambodian can purchase a pack of Marlboro, Camel or 555 and a variety of other brands of international and local tobacco addictives. There are hundreds of them, those tobacco companies who have money are the most prominent. Like Marlboro, it can afford to pay young female crusaders to go around in their colors to advocate its smooth, American cigarette taste.

In Cambodia close to 90% of men smoke, and it's a socially accepted behavior while cigarette companies exploit this practice to their own material benefit. By destroying the health and well being of Cambodian males, tobacco companies continue to become wealthy. This is happening all over the world with cigarette companies capitalizing on vulnerable populations.



# Building On A Dream: A Cambodian Cultural Center

*Chath pierSath*

For some time, the Cambodian Mutual Assistance Association of the Greater Lowell has been looking for a new home. The current office building cannot be upgraded to modern standards. For example, the heating system doesn't work properly. The Young Parent classroom sometimes requires that participants study without heat. During the summer, the building gets too hot due to poor air circulation and ventilation. In addition, the location of the building is not accessible to many people we serve and the office spaces are very limited in size and the building itself is very expensive. The CMAA is currently paying $42,000 a year on the rent.

Two years ago, the CMAA board and the executive director were considering the purchase of the former St. Joseph High School located on 760 Merrimack street. It belongs to the Archdiocese of Boston and it was offered to CMAA for $50,000.

The city government of Lowell was willing to give the $50,000 in grants and another $100,000 as low interest loan for the building renovation project. The CEDAC (Community Economic Development Assistance Corporation) also approved a $10,000 as a low interest loan to cover predevelopment work. However, the building was never purchased.

Today, the CMAA's dream of owning its own home that will be utilized both as an office and as a Cambodian Cultural Center is still alive. The newly elected board members are currently embarking on locating another building, which, if everything works out, is to be the new CMAA's home and the Cambodian Cultural Center of Lowell.




The 80,000 square feet Courier real estate building is located at 165 Jackson Street, in Lowell. If and should this building be given to the CMAA, our dream is to find enough money for its redevelopment and turn it into a Cambodian Cultural Center, which will house many human services and cultural activities that are important to the Cambodian people.

There are more than 20,000 Cambodians who reside in Lowell. Lowell, being a city of immigrants, is home to the second largest Cambodian population in the United States. They have congregated here since the early 1980s.

The Cambodians brought a unique cultural heritage to the city of Lowell. They also brought their hopes and dreams of safety and freedom away from war and the massive violence they experienced during the Khmer Rouge regime.

A Cambodian Cultural Center would serve many purposes for the community in Lowell. The Courier Building is big enough to create many centers within a center. The staff and some of the people they serve are already excited about this possibility. Each staff has already begun to design their office and classroom space. People are envisioning rooms to suit their various programs. These rooms include a

**Continue to page 20**

Continue from page 19

conference hall to hold large conferences or conventions as well as to do training workshops. Some had asked for a kitchen and a banquet room to be built, which can also be rented out to host wedding parties or special social and cultural as well as fundraising events. Others are looking to expand daycare, classroom sizes, have a dance studio for the children to learn and practice their cultural and traditional music, dances and theater. The 80,000 square feet Courier building is even big enough for a religious retreat center where people can get lessons on meditation, learn about Buddhism, hold conferences on peace and non-violence or any other subject of interest. It can even be a place to congregate and do religious ceremonies on New Year celebration or Pchum Ben (Ancestors Day). One staff thought about a movie theater that can also be used for concert, beauty pageant and other cultural and artistic performances. A youth coordinator wants a gym for recreational and sports activities for young people after school, as well as, for old people to do some recreational exercises that will enable them to live longer and healthier lives. An English as a Second Language teacher dreams of having a language lab built into her classroom. These classrooms are also to be used on weekends to teach Khmer language and give adults, through the Cambodian Voter League, weekend citizen classes necessary for Cambodians who want to become American citizens. Other staff thought about a business center to house commercial services like dental and medical clinics, legal services, employment services office, cafe, restaurants, and various retail stores.

"Our dream is to turn the Courier Building into a one-stop center where people can come for social and commercial services at the same time," said Mr. Samkhann Khoeun, Executive Director of the CMAA.

What better use than to develop this Courier building into a business and cultural center? The Uptown District of Middlesex, Appleton and Jacksons streets hungers for human activities to make it more lively and active. Right now, it looks very impressing. A Cambodian business and cultural center would revitalize and attract people into the area and it would generate more money for the city as more people come to visit Lowell.

Imagine, a building where there's a small library that maintains a collection of Khmer as well as English language books and other resources needed by the Cambodian people, but not available to them elsewhere. People will be coming in and out of the building. The district would be a safe place to shop, work, study and congregate for religious purposes. Next to it, there's a technology center with computers and Internet access for our staff, clients and young people to use after school. There will be enough office and professional space to rent out to other Southeast Asian non-profit and community based organizations. Many of them have already expressed an interest in leasing office space. A guest lodge to house Cambodian students, or special master residence artists or any other dignitaries from Cambodia is also on the list. This will be a multi-functional facilities of the 80,000 square feet envisioned through various

Continue to page 23


លិខិតអញ្ជើញ

សមាគមខ្មែរប្រចាំក្រុងឡូវែល និងរៀបចំពិធីជប់លៀងទទួលទានភោជនាហារ និង រាំលេងកំសាន្តក្នុងឱកាសចូលឆ្នាំថ្មី ដើម្បីជួយឧបត្ថម្ភដល់សមាគមខ្មែរអោយមានវឌ្ឍនភាពទៅអនាគត។

អាស្រ័យហេតុនេះ សមាគមខ្មែរមានសេចក្តីសោមនស្សរីករាយ និងសូមអញ្ជើញលោក-លោកស្រី អ្នកនាងកញ្ញា និងប្រិយមិត្ត មកចូលរួមជាភ្ញៀវកិត្តិយស ដែលនឹងប្រព្រឹត្តទៅនៅ៖

**ថ្ងៃសៅរ៍ ទី៥ ខែមេសា ឆ្នាំ១៩៩៧**

វេលាម៉ោង ៦:០០ល្ងាច ដល់ម៉ោង ១២:០០អាធ្រាត

ភោជនីយដ្ឋាន **Park Cafe**

**246 Market St, Lowell, MA 01852**

(មានកន្លែងចតរថយន្តនៅអាគារចតរថយន្តLeo A. Roy ដោយមិនគិតថ្លៃ)

កំដរបរិយាកាសដោយ **វង់តន្ត្រីព្រាននារី**

វិភាគទាន ២០ ដុល្លា (មានទទួលអាហារនិងភេសជ្ជៈ)

សមាគមខ្មែរ នឹងមានបិតិសោមនស្សជាអនេកប្បការ ចំពោះវិភាគទានបន្ថែម

សូមទូរស័ព្ទទាក់ទង

សមាគមខ្មែរ: (508) 454-4286 • ភោជនីយដ្ឋាន: (508) 454-3443

# NICK MANN PRINTING

**COLOR COPY**

NICK MANN
PHONE: (508) 458-4911
FAX: (508) 458-4911

**31 GROTON STREET • LOWELL, MA 01852**

មានបោះពុម្ពសំបុត្រគ្រប់បែបយ៉ាង

***FOR ALL YOUR PRINTING NEED***

| | |
|---|---|
| សំបុត្រអាពាហ៍ពិពាហ៍ | Wedding Invitation |
| កាតពាណិជ្ជកម្ម | Business Card |
| ប័ណ្ណបង្កាន់ដៃ | Receipt Book |
| សំបកកាសែ្សតវីដេអូ | Video Cover |
| សៀវភៅឈ្មោះម្ហូប | Restaurant Menu |
| សេចក្តីប្រកាសផ្សេងៗ | Flyers / Posters |
| និងសំបុត្រផ្សេងៗទៀត... | And Much More... |

**មានទទួលបោះពុម្ពសំបុត្រការ**

**បានឆាប់រហ័សទាន់ចិត្ត**

*Lowell Health Survey Committee:*

Cambodian Mutual Assistance Association
The Laotian Community
Lowell Health Department
UMass Nursing Department
UMass Center for Family, Work, and Community
934-4677

***Learning and Working Together!***

# ជូនចំពោះបងប្អូនជាទីគោរព,

យើងខ្ញុំមានបំណងសុំពេលវេលារបស់លោកអ្នក ចំនួនប្រហែលជា១៥-៣០នាទី ដើម្បីធ្វើការសិក្សាពីផ្នែកសុខភាពរបស់បងប្អូនខ្មែរយើងដែលនៅតាមតំបន់ខ្លះៗនៃទីក្រុងឡូវែល។ យើងខ្ញុំនឹងធ្វើការស្ទង់មតិនេះជាមួយបងប្អូនខ្មែរនិងលាវ ចំនួន១០០គ្រួសារ។ ការស្ទង់មតិនេះគឺចង់ដឹងពីការបារម្ភណ៏ផ្នែកសុខភាពទាំងប៉ុន្មានដែលបងប្អូនយើងមាន និងថា តើលោកអ្នកអាចរកកម្មវិធីថែរក្សាសុខភាពដ៏ល្អសំរាប់គ្រួសារបានឬទេ។ ការស្ទង់មតិនេះនឹងជួយយើងខ្ញុំឲ្យយល់អំពីបញ្ហាទាំងឡាយដូចជាជាតិសំណពុលដែលបងប្អូនយើងខ្លះៗដែលរស់នៅក្រុងឡូវែលនេះបានពើបប្រទះ។

គេនឹងមិនបង្ហាញចំលើយរបស់លោកអ្នកទៅឲ្យអ្នកណាម្នាក់ឃើញឡើយ! ចំលើយទាំងនេះនឹងត្រូវគេបូកបញ្ចូលជាមួយចំលើយទាំងឡាយ ដើម្បីជាជំនួយដល់សហគមន៏ក្នុងការសិក្សាចាំបាច់ផ្នែកសុខភាព និងសំណួរទាក់ទងដល់សុខភាពដែលបងប្អូនរស់នៅក្រុងឡូវែលមាន។ លទ្ធផលដែលយើងបានមកនឹងត្រូវគេរៀបចំឲ្យបានជារបាយការណ៏សហគមន៏មួយ ហើយចែកចាយជាមួយគិលានុបដ្ឋាកតាមសាលារៀន អ្នកណែនាំផ្នែកសុខភាព មេដឹកនាំសហគមន៏ ដើម្បីឲ្យយើងអាចធ្វើការរួមគ្នា បង្កើតបានជាសហគមន៏មួយដ៏ល្អប្រសើរផ្នែកសុខភាព។

**តើការស្រង់មតិនេះបានមកដោយរបៀបណា? ការស្រង់មតិនេះ គឺបានបង្កើតឡើងដោយ**ការចូលរួមជាមួយក្រុមដ៏ទៃផ្សេងៗទៀតជាច្រើន។ ក្នុងឆ្នាំកន្លងមកនេះ អ្នកដឹកនាំពីសហគមន៏បុគ្គលិកពីក្រសួងសុខាភិបាលក្រុងឡូវែល សមាគមខ្មែរ សមាគមលាវ ហើយនិងមកពីមហាវិទ្យាល័យផ្នែកសុខាភិបាល និងមជ្ឈមណ្ឌលសំរាប់គ្រួសារ ធ្វើការនិងសហគមន៏របស់សាកលវិទ្យាល័យម៉ាស្សាឈូសិត បានធ្វើការរួមគ្នាដើម្បីស្រាវជ្រាវរកនូវបញ្ហា ផ្សេងៗដែលទាក់ទងទៅនឹងសុខភាព និងបរិយាកាសដែលបងប្អូនមានបំណងចង់ជ្រាប។ ការស្ទង់មតិនេះ គឺជាលទ្ធផលនៃការប្រឹងប្រែងដែលបានមក។

សូមអរគុណ ចំពោះការជួយជ្រោមជ្រែងរបស់បងប្អូន។ សូមជំរាបថា លោកអ្នកមានសិទ្ធិអាចបដិសេធមិនចូលរួមក្នុងការស្រង់មតិនេះក៏បាន ហើយនិងមិនចាំបាច់ឆ្លើយនូវសំណួរណាមួយដែលលោកអ្នកមិនចង់ក៏បានដែរ។ ចំលើយរបស់លោកអ្នកនឹងត្រូវទុកជាការសំងាត់។ ប្រសិនបើលោកអ្នកមានចំងល់ផ្សេងៗ ដែលទាក់ទងនឹងការស្ទង់មតិនេះ សូមមេត្តាទូរស័ព្ទទៅលេខ ៩៣៤-៤៦៧៧ សួររក **Dr. Linda Silka** , Director, Center for Family, Work, and Community, University of Massachusetts, Lowell, 01854, Phone: 934-4677 ។

ដោយសេចក្តីរាប់អាន,

**Continue from page 12**

for each child per day. And children are provided with medical insurance in order to taken care of for medical, dental and optical problems.

Applicants must attend a ten-week training session. The sessions are held one night a week for ten weeks. Applicants need to provide the department with references and applicants will have a Criminal Records Check completed on all household members over the age of fourteen.

Please contact Susan Tucke or Michael Ben Ho at 452-8970 to discuss obtaining an application packet.

# រដូវក្តៅនូវតាមដងស្ទឹងបើមោក

**ដោយ ថា ឆៃច**

១

**សែន** រសាប់រសល់! ខ្យល់ជំនោរបក់រសៀកៗ មកបបោសអង្អែលធម្មជាតិ នៅតាមដងទន្លេរ ឲ្យកាន់តែមានភាពស្រងូតស្រងាត់ឡើង។ រលករត់រមិញប្រដេញគ្នាមកបោកប្រាណនឹងជញ្ជាំងច្រាំងថ្មម្តងហើយ ម្តងទៀត ឥតឈប់ឈរ ហាក់ដូចជាជីវិតសត្វលោកដែលចេះតែប្រឈមមុខជាមួយនឹងឧបស័គ្គ នឹងការភ្ញើតភ្ញើន នឹងសេចក្តីត្រូវការ នឹងមហិច្ឆិតា ជានិច្ចនិរន្តរ៍។ នៅឯនាយខាងត្រើយឯនោះ ចុងរុក្ខជាតិមានចលនារេរាំទន់ទោរ ចុះឡើងហាក់ដូចជាគ្មាននឿយណាយសោះ។ ទិដ្ឋភាពខាងក្រោយ ឆ្ងាយបន្តិចពីនេះទៅទៀត ជាផ្ទៃមេឃពណ៌ខៀវស្រឡះថៃស លាយលំអដោយកាំទេចឆពណ្ណរង្សី នៃព្រះសូរ្យសែងនៅពេលអស្តង្គត។ ទេសភាពបែបនេះនរណាក៏មានអារម្មណ៍លង់លក់ដែរ! អ្នកច្បាស់ជាស្រងេះស្រងោចមិនលែងបើសិនជាអ្នកជាទេសចរមកពីទីដទៃ! អ្នកប្រាកដជាកណ្តោចចិត្តមិនខាន ប្រសិនជាអ្នកបានបែកចេញពីភូមិស្ថានជាយូរមកហើយ! ហើយអ្នកមុខជារសាប់រសល់ តប់ប្រមល់ក្នុងចិត្តជាពន់ពេក បើសិនជាអ្នកត្រូវរង់ចាំនរណាម្នាក់។

- សួស្តី! វិនដា, សុខសប្បាយជាទេ?

សម្លេងដ៏ចម្លែកនេះហាក់ដូចជាធ្វើឲ្យបរិយាកាសទាំងមូលប្រែផ្លាស់ជាបន្ទាន់។ សក់ នាងវែងប្រាសស្មា ខ្មៅរលីបរលោង រលាស់ទន់ភ្លន់ ស្របជាមួយទឹកមុខនាង ដែលញញឹមប្រិមប្រិយ។ នាងក្រោកឈរបង្ហាញនូវរាងនាងខ្ពស់ស្រឡះ ដៃជើងនាងវែងរលូនសាកសមនឹងរូបរាង។ នាងយកដៃទ្រចង្កាស្លូចសមឥតខ្ចោះ រោមភ្នែកងរខ្មើត បបូរមាត់ស្តើងក្រហមច្រាលពីធម្មជាតិ នាងងាកបែរដោយរហ័សទៅរកសម្លេងសួរ រួចធ្វើឫកម្ញក់ពើយបែរត្រឡប់ទៅគយគន់ខ្សែទឹកហូរទៅវិញ ព្រមជាមួយវាចាដែល ស្រួយស្រេះ-----

- សួស្តី! បូទី, ខ្ញុំសុខជាទេ? --- តែ
- តែ --- តែ មិនសូវសប្បាយមែនទេ?
- ហ៊ឺ! --- តើប្អូនឯងអាចទៅរកសេចក្តីសុខផងសប្បាយផងឯណាបានទៅអេះ! --- បើ
- បើ --- បើវាយ៉ាងម៉េច? នែ! វិនដា! ខ្ញុំប្រាកដជារកវាបាន។ ព្រោះថាសេចក្តីសុខសប្បាយ ត្រូវការមានគ្នា!
- គ្នាប៉ុន្មាននាក់ទៅ? ខ្ញុំជឿថា មានគ្នាច្រើនកាលណា សេចក្តីទុក្ខក៏កាន់តែមានច្រើនកាលនោះ --- នេះបើតាម ---
- បើតាមធម៌ព្រះពុទ្ធ មែនទេ? (សម្លេងសើច --- )
- មែនហើយមានរូបមានទុក្ខ ប្អូនឯងដឹងទេ?
- អូ! សំណាងហើយ វិនដាឯងនិយាយជាមួយខ្ញុំជាអ្នកកាន់ពុទ្ធសាសនា, ម្ល៉េះសមនិយាយមិនយល់គ្នាឡើយ! (សូរសម្លេងសើចក្អាកក្អាយ)
- មែនហើយ!បូទី, យើងជាមិត្តរួមថ្នាក់តាំងពីកាលដែលយើងនៅពីតូចៗម្ល៉េះ។ ការពិតពួកយើងកម្រផ្តោះប្តូរយោបល់គ្នាណាស់។ តើមកពីហេតុអ្វី?
- មានហេតុអ្វីក្រៅពីយើងមានភេទខុសគ្នានោះអី? (អ្នកកម្លោះយើងនិយាយបណ្តើរ ភ្នែកសម្លឹងទៅឯទីឆ្ងាយបណ្តើរ ជួនពេលខ្លះទៀត នាយដកដង្ហើមធំផង។)
- ពុទ្ធោ! មកពីភេទ? មកពីខ្ញុំជាស្រីភេទ ដែលគេកំពុងសំគាល់ទុកថាជាភេទទន់ខ្សោយ គួរតែនៅចាំផ្ទះ គួរតែជាអ្នកចាំតែថែរក្សាបីបាច់កូន គួរចាំតែ ស្តាប់បង្គាប់ប្តី គួរតែ --- ហ៊ឺ --- ដូចម្តាយខ្ញុំ --- (ទាំងទឹក មុខគ្នាន់ខ្នាញ់) មិនបាច់ចាំរៀនឲ្យ ចេះដឹងជ្រៅជ្រះអ្វីទេ!
- ហា! ហា! ហា! នេះបានត្រូវចំណុចមែន! ណ្ហើយ! កុំអាលប្រឡោតមើលនោះ! ឃើញទេ?

(នៅមានត)


# Business Opportunity

## FOR SALE
## Delicatessen and Variety Store
## Plus Real Estate

Includes:

- Beer and Wine License
- Lottery Sales
- Equipment

Located in Haverhill, Mass.
$175,000

**Contact broker: Peter T. Victory**
**Tel: (508) 745 2593**
**8 Lee Street, Salem, MA 01970**


**Continue from page 20**

people. The possibilities are limitless.

This Cambodian Cultural Center, which will be named the Conway Khmer Community Center in honor to the donor, the Conway Family, will also provide jobs for Lowell residents. With this building, the CMAA will be able to expand its current human service programs and take on bigger economic and community development projects. It will host various learning and cross-cultural exchanges between local, state and federal institutions and the Cambodian community. The

**Continue to page 24**

# ប្រជាធិបតេយ្យ គឺជាអ្វី !

ដកស្រង់ចេញពីសៀវភៅ **"ប្រជាធិបតេយ្យក្នុងលោក"** សោម នរេត

**ម្យ៉ាង**វិញទៀត មនុស្សកើតឡើងនៅក្នុងសង្គមជាដរាប។ ឯការនៅក្នុងចំណោមមនុស្សឯទៀត បណ្ដាលឲ្យមានកិច្ចរៀបចំសង្គមជាមិនខាន។

ដូច្នោះ ដើម្បីរស់គោងធ្វើការ ហើយដើម្បីរៀបរយមនុស្សតោងតុបតែងសង្គម។

មនុស្សភាគច្រើនធ្វើការហូរញើសហូរឈាមទល់មកដល់សព្វថ្ងៃ។ មនុស្សក៏បានខំព្យាយាមរៀបចំសង្គមដោយច្រើនបែបច្រើនបទណាស់ដែរ។ ក៏ប៉ុន្តែ សេចក្ដីព្យាយាមទាំងនោះនាំឲ្យមនុស្សនៅតែមានសេចក្ដីវេទនាដដែល។ បើពោលដោយសង្ខេប ប្រវត្តិលោកជាប្រវត្តិតស៊ូរបស់មនុស្សប្រឆាំងនឹងធម្មជាតិប្រឆាំងនឹងមនុស្សគ្នាឯង ប្រឆាំងនឹងអាត្មាខ្លួនឯងទៀត។ ជាប្រវត្តនៃញើស នៃឈាមនៃទឹកភ្នែកមនុស្ស។ ម្ដេចរឿងនេះនៅតែដដែល បើមនុស្សភាគច្រើនខំរើយ៉ាងនេះដែរ។

ពាក្យឆ្លើយដោយខ្លីៗនោះគឺមនុស្សពីមុនៗមក ពុំទាន់មានអនុភាពខ្លាំងប៉ុន្មានទេលើធម្មជាតិ ដោយវិទ្យាសាស្ត្រនៅស្ដួចស្ដើងទើបបង្កើតផលមិនបានហូរហៀរ។ ម្យ៉ាងទៀតរបបគ្រប់គ្រងដែលទេសកាលផ្សេងៗ បានដឹកលំឲ្យមានរៀងមកនោះ សុទ្ធសឹងជារបបដែលឋិតលើការរឹបជាន់នៃមនុស្សភាគតិចជិះកមនុស្សភាគច្រើនដែលជាអ្នកបង្កើតផលនោះ ព្រោះហេតុនេះហើយទោះបីពួកណាឡើងកាន់អំណាចក៏ដោយ ពួកនោះការពារតែប្រយោជន៍ពិសេសរបស់គេប៉ុណ្ណោះ ពីព្រោះក្រុមគេជាក្រុមដោយឡែកអំពីរាស្ត្រសាមញ្ញ ឯពាក្យដែលគេថាធ្វើការដើម្បីប្រយោជន៍សាធារណៈនោះ ជាពាក្យបោកបញ្ឆោតទាំងអស់។ ម៉្លោះហើយក្នុងរបបបែបនេះ រាស្ត្រនៅតែខ្ញុំគេជាដរាប។ បើមានការផ្លាស់ប្ដូរដល់អ្នកកាន់អំណាច រាស្ត្រគ្រាន់តែផ្លាស់ម្ចាស់ប៉ុណ្ណោះ តែឥតផ្លាស់ឋានៈខ្លួនជាងគេឡើយ។ នេះជាហេតុបណ្ដាលឲ្យមនុស្សភ្ញាក់គិតឃើញថា មានតែរាស្ត្រទេដែលធ្វើឲ្យរាស្ត្រមែនៗ។

នេះជាដើមកំណើតនៃប្រជាធិបតេយ្យ។

<u>ន័យដើមរបស់ពាក្យប្រជាធិបតេយ្យ:</u>

គេអាចបំបែកពាក្យប្រជាធិបតេយ្យជាវត្ថុពីរពួកគឺ: " ប្រជា " ដែលមានន័យថា ជនទាំងឡាយ រាស្ត្រ មួយទៀតគឺ: "អធិបតេយ្យ" "ដែលមានន័យថា អំណាចខ្ពស់បំផុត។ដោយហេតុនោះ ន័យដើមរបស់ពាក្យ ប្រជាធិបតេយ្យគឺ "<u>រាស្ត្រកាន់អំណាចខ្ពស់បំផុត</u>"។ បើនិយាយដោយពាក្យស្លោកគេអាចពោលថាបានប្រជាធិបតេយ្យ "រាស្ត្រជាធំ" គឺធ្វើអ្វីៗសំរាប់រាស្ត្រទាំងអស់ តាមតែចិត្តរាស្ត្រ ដោយស្នាដៃរាស្ត្រ។ ដោយរឿងនេះជារឿងដែលគេតែងដឹងឮញឹកញាប់ណាស់មកហើយ ទើបយើងគ្រាន់តែយកពាក្យសុភាសិតខាងលើនេះមកបំបែកសេចក្ដីដោយខ្លីៗប៉ុណ្ណោះ ប្រយោជន៍ជាកិច្ចបង្រួបអង្គរឿងដូចតទៅ។

រាស្ត្រគឺបណ្ដាមនុស្សគ្រប់ភេទ ទាំងស្រីប្រុស ដែលនៅក្នុងសង្គមនិមួយៗ។ រាស្ត្រមិនមែនបុគ្គលនេះ ឬបុគ្គលនោះទេ មិនមែនពួកនេះ ឬពួកនោះទេ មិនមែនវណ្ណៈនេះ ឬវណ្ណៈនោះទេ។

ដែលហៅថាធ្វើអ្វីៗ ដើម្បីរាស្ត្រទាំងអស់នោះគឺ យកសេចក្ដីសុខនិងចំរើនរបស់រាស្ត្រជាគោលបំណងនៃសកម្មភាពសព្វគ្រប់ក្នុងសង្គម មិនមែនធ្វើការសំរាប់ជនណាមួយ ជនឯណាមួយក្រុម ឬធ្វើការសំរាប់អាទិទេពឯណាមួយឡើយ។ ធ្វើការសំរាប់រាស្ត្រ គឺធ្វើការសំរាប់មនុស្សទូទៅ ដែលរស់ក្នុងសង្គមនិមួយៗ។

ធ្វើតាមចិត្តរាស្ត្រ គឺយកចិត្តរាស្ត្រជាធំយកឆន្ទៈដែលរាស្ត្របានបញ្ចេញមកដោយសេរីនិងដោយរឿងច្បាស់លាស់នោះ ជាច្បាប់បញ្ញត្តិដើម្បីធ្វើការតាមរាល់ពេលវេលា គឺមិនមែនធ្វើតាមចិត្តអ្នកណាមួយរូប ឬមួយក្រុម ឬតាមគតិចិត្តនៃអាទិទេពឯណាឡើយ។

ធ្វើការដោយដៃរាស្ត្រ គឺចាត់ការបដិបត្តិការ ព្រមទាំងជំរះរឿងស្មុគស្មាញដែលអាចកើតឡើងបាននោះដោយរាស្ត្រទៀត គឺមិនប្រគល់ខ្លួនទៅឲ្យអ្នកណាចាត់ការជួសការជួលដោយរាស្ត្រត្រូវតែទទួលលទ្ធផលនោះល្អ ទោះអាក្រក់អស់នោះទេ។

យើងដឹងហើយថា ទាល់តែគេយកលក្ខណៈទាំង បីប្រការខាងលើនេះមកប្រើជាមួយតែម្ដងហើយ រាល់ពេលវេលាទៀត ទើបប្រយោជន៍រាស្ត្រនឹងមានទីអះអាងការពារដោយគ្រប់គ្រាន់។

<u>ប្រជាធិបតេយ្យពិតៗមានលក្ខ័គោលជាក់លាក់ជាទីសំគាល់និងជាទីអាង:</u>

តែគំនិតអ្វីៗទាំងអស់នោះ ទោះបីល្អប្រពៃយ៉ាងណាក៏ដោយ ក៏នៅជាការឥតអំពើដដែលទៀត បើគ្មានអង្គការអ្វីសំរាប់បដិបត្តិទៅតាមនោះឲ្យបានពេញលេញផងទេ។

ដោយហេតុនោះ ពាក្យសុភាសិត "<u>ធ្វើអ្វីៗសំរាប់រាស្ត្រទាំងអស់ តាមតែចិត្តរាស្ត្រ ដោយស្នាដៃរាស្ត្រ</u>" អាចយកមកប្រើបានលុះណាតែមានគោលការណ៍ជាក់លាក់សំរាប់ប្រតិបត្តិតាមនោះមកផ្ទាប់ពីខាងក្រោយផង។ វិធានការណ៍ដែលត្រូវមានអាចចែកបានក្នុងនាទីធំៗ ដូចតទៅ:

(នៅមានត)

**Continue from page 23**

dream is to build collaborations and the kind of intercultural exchanges that will be beneficial to all communities across racial and ethnic lines. This Center can be a way for Cambodians to learn about other people and the political and social system of their new home. It can be a channel that attracts human and financial resources to carry out various community development projects here in Lowell and in Cambodia. People outside the community can also use the Center as a resource for their work. The exchange will be very beneficial to all who are involved in our endeavor to serve our community at large. To find out how you can support this project, please call Samkhann Khoeun at CMAA 508-454-4286.

# កាព្យបណ្ដាំ

ដោយ ពៅ ពេញចិន្ដា

សំនៀងត្រដោក  សោកសៅសង្វេក  សម្លេងទ្រស្រែក
ត្រដើតត្រដក់  ក្រលរក្រលួច  ព្រួចចិត្តជូរចត់
ហៅសែនកំសត់  ព្រាត់មេព្រាត់បា។

សាដៀវអុកទូញ  ទំនួញត្អូញត្អែ  ត្អូញប្រាប់អោយខ្មែរ
បែរសាមគ្គីគ្នា  រកសន្ដិភាព  ដល់រដ្ឋប្រជា
លើកដៃពានា  រំលឹកបុព្វជន។

ឱភ្លេងរនាត  អ្នកលាតសន្ទឹង  លេងបទកន្ទ្រឹម
រលឹមប្រិចៗ  ស្រុកកើតសង្គ្រាម  ឈាមរាចដូចទឹក
ខ្មែរកើតទុរភិក្ស  ភ័យន្ដរាយ។

រលកខ្ទុយយំ  ទ្រនំទឹកភ្នែក  ចុកចាប់អនេក
ស្រែកយ៉ាងឈឺផ្សារ  ពាំពាក្យម៉ឺនម៉ាត់  ប្រាប់បុត្រគ្រប់ឋា
អោយខំរក្សា  រដ្ឋាសុវ័ណ្ណ។

ឥឡូវរដ្ឋា  ខ្ទោចផ្សារពេកក្រៃ  អភិជនប្រុសស្រី
ឈ្លក់និងបុណ្យស័ក្តិ  ខ្វាយជាស្នោជន  ទ្រ័ព្យធនជាច្បាប់
ចិត្តជូរអប្បលក្ខណ៍  ខ្វាក់និងអំណាច។

ខ្មែរអើយក្រោកឡើង  ដំកើងខេមរា  ទោះនៅទីណា
ភាសារជាគោល  មិនត្រូវរលត់  ដោយឥតស្រមោល
អ្នកជាបង្គោល  សរសទ្រូងជាតិ។

ភាសារលត់  ជាតិខ្មែររលាយ  នេះជាទំនាយ
តម្រាបូរាណ  អ្នកជាបេះដូង  នៃភាពក្សេមក្សាន្ត
សូមជនគ្រប់ប្រាណ  ទឹកគិតអោយល្អិត។

គួរណាស់ស្ដាយជាតិ  រាជរដ្ឋគីរី  សង្គ្រាមយារយី
ជាន់ឈ្លីលិចលង់  ឮតែបទភ្លេង  ខ្មែរលេងប្រគំ
ច្រៀងរៀងខ្មែរយំ  ដង្ហោយហៅញាតិ។

សូមជាតិខេមរា  បីបាច់កូនចៅ  ខិតខំប្រដៅ
កុលបុត្រប្រុសស្រី  អោយចេះស្ដាប់ភ្លេង  ទុក្ខសោកចាប៉ី
អោយស្គាល់យល់ន័យ  បទសាវតារខ្មែរ។

បណ្ដាំគ្រប់ឃ្លា  ជ្រាបពេញបេះដូង  សូមខ្មែរស្រុះឡើង
គ្រប់ទិសប្រជា  អោយស្គាល់ជាតិឯង  កុំក្រែងនិងគ្នា
ចូរជនរាល់គ្នា  រក្សាសំដៅ។

ព្រលឹងខេមរៈ  រសាត់វិលវល់  ព្រោះនៅតិតខ្វល់
ដល់បុត្រខេមរា  ទន្ទឹងថ្ងៃស្អែក  ព្រះអាទិត្យភ្លឺថ្លា
ស្រុកទេសថ្ងៃថ្លា  ចិន្ដារីករាយ។

## សេចក្ដីជូនដំណឹង អំពីកម្មវិធីសិក្សានៅ សមាគមខ្មែរប្រចាំទីក្រុងឡូវែលើ

កម្មវិធីសិក្សាអក្សរសាស្ត្រខ្មែរ និងបើកទទួលសិស្សថ្មីទៀតពីថ្នាក់ដំបូងរហូតដល់ថ្នាក់ខ្ពស់។ សូមជម្រាបថាថ្នាក់បង្រៀនអក្សរខ្មែរសព្វថ្ងៃមានសិស្សចំនួន៦០នាក់ហើយ និងកំពុងតែមានដំណើរការល្អប្រពៃឡើងក្នុងកម្មវិធីនេះក៏មានសិស្សអាមេរិកាំងចូលរៀនជាច្រើនផងដែរ។



យើងខ្ញុំជឿជាក់ថា លោកអ្នកនឹងបញ្ជូនកូនមករៀនមិនខុសបំណងឡើយ។ ម្យ៉ាងទៀតសមាគមខ្មែរមានបើកថ្នាក់បង្រៀនភាសាអង់គ្លេសសំរាប់មនុស្សចាស់ៗ និងហ្វឹកហ្វឺនអោយធ្វើតេសសំរាប់ចូលសញ្ជាតិ អាមេរិកាំងផង។

- ថ្នាក់បើកបង្រៀនពីម៉ោង ៩:០០ ដល់ម៉ោង ១១:០០ព្រឹក រៀងរាល់ថ្ងៃអាទិត្យ លើកលែងតែថ្ងៃបុណ្យ។
- ☎ ពត៏មានផ្សេងៗ សូមទាក់ទងលោក កែ ប៉ាហ៊ីម, ធីម្មាធី មុត ឬ ឆនអាន តាមទូរស័ព្ទលេខ ៤៥៤-៤២៨៦។

# សន្តិភាព

**អត្ថបទដកស្រង់ចេញពីសៀវភៅ**
**" ស្រីហិតោបទេស "**

សោម នរេត

៨- របស់ណាមិនមានបច្ច័យរបស់នោះក៏តែងមិនមាន ថាបើរបស់ណាមានបច្ច័យ របស់នោះក៏មិនមែនជាផទៃ។ ថ្នាំនេះរំងាប់ពិសពុលគឺសេចក្តីពិតបាន ហេតុដូចម្តេចហ្ន៎ ក៏គេមិនដឹងថ្នាំនោះ។

កាលនោះឯង ត្រីប្រត្យុត្បន្នមតិកំពុងតែគិតដូច្នេះ ត្រូវព្រានប្រមង់ពាក់មងជាប់ ទើបធ្វើពុតដូចជាខ្លួនស្លាប់ ឋិតនៅស្ងៀមឥតខ្ទើកឡើយ ដល់ព្រានប្រមង់ដោះចេញពីមងរួចហើយ ក៏ខំបំរះនឡៀលពេញទំហឹង លោតចូលទៅក្នុងទឹកជ្រៅភ្លាម។ ឯត្រីយ៉ទភវិស្សតិព្រានប្រមង់ចាប់បានហើយចោកសំលាប់ទៅ។ ព្រោះហេតុនោះ បានជាខ្ញុំ (អណ្តើកកម្ពុគ្រីព) ពោលថា "ត្រីអនាគតវិធាតា" ដូច្នេះជាដើម(លេខ៦)។ ហេតុការណ៍ដូចខ្ញុំ(អណ្តើកកម្ពុគ្រីព) បានពណ៌នាមកនេះ សូមមិត្រជួយចាត់ចែងឲ្យបានខ្ញុំចេញទៅកាន់ស្រះដទៃក្នុងពេលនេះទៅ "។ ហង្សទាំងពីរតបថា: "បើបានទៅដល់ជលាស័យដទៃហើយ ជាកុសលសំលាញ់ឯងហើយ តើសំលាញ់នឹងទៅដោយវិថីតាមវិធីណា? "។

អណ្តើកពន្យល់ឧបាយថា: "អើ! គិតរកវិធីណាដែលទៅតាមអាកាសជាមួយសំលាញ់ទាំងពីរនាក់បានហើយ "។ ហង្សទាំងពីរសួរទៅទៀតថា: "ឧបាយនេះ សំលាញ់គិតថានឹងឲ្យសំរេចបានបែបយ៉ាងណា? "។ អណ្តើកឆ្លើយប្រាប់ទៅវិញថា: "នែសំលាញ់ យកកំណាត់ឈើមួយមកហើយសំលាញ់ឯងទាំងពីរនាក់ពាំចុងកំណាត់ឈើម្ខាងម្នាក់ដោយចំពុះ ខ្ញុំខាំកណ្តាលគោងកំណាត់ឈើនោះ ដោយវិធីនេះហើយអាស្រ័យដោយកំលាំងស្លាបសំលាញ់ហើរទៅ ខ្ញុំនឹងទៅបានដោយស្រួល "។ ហង្សទាំងពីរឆ្លើយតបមកដោយអរថា: "អើ! ឧបាយនេះស្រួលហើយ តែត្រូវគិតថា:

៩- អ្នកប្រាជ្ញ កាលគិតដល់សេចក្តីចំរើនហើយ ត្រូវគិតដល់សេចក្តីវិនាសផង កុកល្ងង់គិតឃើញសេចក្តីចំរើនតែម្យ៉ាង ត្រូវស្ពាស៊ីកូនខ្មុក "។

អណ្តើកសួរដេញដោលថា: "រឿងនេះតើដូចម្តេច? "។ ហង្សទាំងពីររៀបរាប់ប្រាប់ថា:

**រឿងកុក ០ស់ទិងស្ពា**

ក្នុងឧត្តរាបថ, នៅលើភ្នំគិជ្ឈកូដ មានបិប្បលិព្រឹកមួយដើមធំ ជាទីអាស្រ័យនៅនៃកុកទាំងឡាយ។ ពស់វែកមួយអាស្រ័យនៅក្នុងព្រង់ឫសខាងក្រោមឈើនោះ វាតែងតែវាលូនចូលទៅចាប់យកកូនកុកស៊ីជាចំណីអាហារ អស់កាលជានិច្ច។ ចំណេរកាលមក, កុកល្ងង់មួយលុះបានឮសំលេងយំខ្សៀវខ្សានៃកុកទាំងឡាយដែលមានសេចក្តីសោកបៀតបៀនហើយ ក៏និយាយឡើងថា: "នែអ្នកទាំងឡាយ! អ្នកកុំយំថ្វី ចូរធ្វើតាមឧបាយកលខ្ញុំវិញ យើងត្រូវទៅរកចាប់ត្រីយកមករាយតៗគ្នាតាំងពីព្រង់ស្ពាឲ្យរហូតដល់ព្រង់ពស់ ឯសត្វស្ពាជាសត្វជាប់ចិត្ត ដោយអាហារគឺត្រីនោះនឹងចេះតែដើររៀងមកដល់ព្រង់ពស់ កាលឃើញពស់ជាសត្វសត្រូវពីកំណើតស្រាប់ មុខជានឹងខំាពស់សំលាប់ដោយក្តីសំអប់មិនខាន "។ កុកទាំងឡាយក៏ព្រមព្រៀងគ្នាធ្វើតាមពាក្យកុកល្ងង់នោះ។ ក្នុងកាលនោះឯង, សត្វស្ពាដែលនៅក្នុងព្រង់ឈើនោះ បានឮសំលេងកុកយំអឺងកង ក៏វារឡើងដើមឈើនោះពីខាងម្ខាង ស្រង់តាមក្លិនត្រីនោះ ឃើញត្រីហើយស៊ីត្រីនោះៗបណ្តើរមក មិនស៊ីតែត្រីស៊ីទាំងសាវកកុកអស់រលីងថែមទៀត, ព្រោះហេតុនោះហើយបានជាខ្ញុំពោលថា: "អ្នកប្រាជ្ញ កាលគិតដល់សេចក្តីចំរើនហើយ "ដូច្នោះជាដើម(លេខ៩)។ មិនថ្វីទេ យើង(ហង្សទាំងពីរ)នាំទៅបាន តែកាលដែលយើងនាំសំលាញ់ទៅនោះ មុខជាមនុស្សលោកមើលឃើញ កាលបើឃើញហើយនឹងនិយាយឆោឡោអឺងកងឡើងមិនខាន, បើសំឡាញ់បានឮសំលេងមនុស្សលោកហើយអត់ទ្រាំមិនបាន ចង់ឆ្លើយតបគេវិញ មុខជាសំលាញ់នឹងធ្លាក់ក្លួកដល់ដីស្លាប់អសារបង់មិនខានទេ ចូរសំលាញ់តាំងចិត្តដាច់ស្រេចនឹងនៅក្នុងទីនេះទៅល្អជាង "។ អណ្តើកនិយាយរឹងទទឹងទៅទៀតថា: "បើមែនដូចថា, រូបខ្ញុំនឹងត្រូវគេសំគាល់ថាជាអ្នកឥតចេះដឹងអ្វីទៅហើយឬ? មួយទៀត, បើរូបខ្ញុំឆ្លើយតបនឹងគេវិញហើយតើ វាហើយគ្នាទៅហើយ អ្នកណាក៏មិនត្រូវនិយាយថាដូចម្តេចទៀតដែរ "។ សត្វទាំង៣ និយាយពិគ្រោះគ្នាហើយ ក៏ធ្វើតាមពាក្យដែលនិយាយនោះ។ កាលនោះ, ក្មេងគង្វាលគោក្រឡេកមើលទៅឃើញហង្សទាំងពីរនាំអណ្តើកហោះហើរដើរ លើអាកាសវេហាស៍ដូច្នោះ ក៏ស្រែកនិយាយជជែកគ្នាឆោឡោទ្រហឹងអឺងកងឡើងហើយរត់ដេញតាមទៅ ក្មេងខ្លះនិយាយចំអកឡកឡឺយថា: "កាលណាអណ្តើកធ្លាក់មកដល់ដី កាលនោះយើងនឹងយកវាទៅស្ងូការីស៊ីឲ្យឆ្ងាញ់ម្តងរ៉ឺយ " ក្មេងខ្លះទៀតនិយាយកំញើញថា: "ទេ! យើងយកទៅដុតស៊ីឥឡូវនេះឯង " ក្មេងខ្លះតទៅទៀតនិយាយឡកថា: "ទេ! យើងយកទៅស្ងូស៊ីឯផ្ទះវិញ "។ ឯអណ្តើកនោះ លុះឮពាក្យក្មេងគង្វាលគោនិយាយឡកឡឺយឲ្យមុខគួរក្តាញ់ ក៏ភ័ន្តស្មារតីភ្លេចពាក្យដែលនិយាយមុននោះ បែរទៅជាហាមាត់និយាយឆ្លើយតតបទៅវិញថា: "នែរ៉ឺយ! អាក្មេងអាឯងទាំងអស់គ្នាស៊ីតែផេះទៅចុះ "។ កាលដែលអណ្តើកហាមាត់និយាយដូច្នេះ ក៏ធ្លាក់ក្លួកមកដល់ដី បានដៃក្មេងដុតស៊ីជាចំណីអាហារទៅហោង ព្រោះហេតុនោះបានជាខ្ញុំ(ចាក្រពាកសវិជ្ជ:) ពោលថា: "នរជនណាមិនត្រេកអរនឹងពាក្យដាស់តឿននៃមិត្រ " ដូច្នោះជាដើម(លេខ៣) ក្នុងកាលនោះឯង, កុកជាចារបុរសដើរចូលមកក្នុងទីនោះហើយនិយាយឡើងថា: "ទេវ:! និយាយធ្វើអ្វី ខ្ញុំបាទបានប្រាប់ប្រងតាំងពីកាលនោះម៉្លេះថា ត្រូវចាត់ចែងបន្ទាយឲ្យឆាប់រួសរាន់ទៅ តែលោកម្ចាស់មិនធ្វើតាមពាក្យខ្ញុំបាទ ហេតុនោះហើយបានជាលោកម្ចាស់ត្រូវសោយផលនៃការព្រងើយកន្តើយក្នុងកាលនេះឯង, ឯការដុតបំផ្លាញបន្ទាយយើងនេះ គឺក្អែកមេឃពណ៌នេះឯងដែលត្បាតទុរទសីប្រធានរដ្ឋមន្ត្រីសត្រូវប្រើមកឲ្យធ្វើការ "។ រាជហង្សហិរណ្យគភ៌:ដកដង្ហើមវែងៗ ហើយពោលថា:

១០- នរជនណា ស្និទ្ធស្នាលចំពោះសត្រូវដោយការរាប់អានក្តី ដោយយល់ឧបការ:ក្តី នរជននោះ ទុកដូចជាមនុស្សដេកលក់លើដើមឈើហើយភ្ញាក់ធ្លាក់មកដល់ដីទើបភ្ញាក់ដឹងខ្លួន។

(នៅមានត)

# KHMER LOWELL

ខ្មែរឡូវែល ជាព្រឹត្តិបត្រចេញផ្សាយប្រចាំខែ រៀបចំឡើងដោយសមាគមខ្មែរក្រុងឡូវែល, ក្រុមអ្នកបោះឆ្នោតខ្មែរ-អាមេរីកាំង, និងវិទ្យាស្ថានវប្បធម៌ខ្មែរ។ យើងសូមស្វាគមន៍ចំពោះវិភាគទាន ជាអត្ថបទគ្រប់យ៉ាង ដូចជា៖ កំណាព្យ, រឿងប្រឌិត, រឿងកំប្លែងខ្លីៗ រូបថតដែលមានសារៈសំខាន់សំរាប់អ្នកអានទូទៅ។ល។ សូមមេត្តាកំណត់ប្រវែងអត្ថបទនិមួយៗ អោយមានត្រឹមតែពី ៨០០-១២០០ពាក្យ ហើយអត្ថន័យនៃអត្ថបទនោះសោត ត្រូវមានលក្ខណៈស្របទៅតាមគោលគំនិតរបស់ព្រឹត្តិបត្រខ្មែរឡូវែលយើងផងដែរ។ ម្យ៉ាងវិញទៀត, សូមលោក-លោកស្រី អ្នកនាងកញ្ញា ដែលជាម្ចាស់អត្ថបទសូមមេត្តាសរសេរឈ្មោះ, អាស័យដ្ឋាន, និងហត្ថលេខាអោយបានច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការទាក់ទងតាមរយៈប្រៃសណីយ៍។

ចំពោះអត្ថបទដែលយើងមិនអាចផ្សាយបានដោយបុព្វហេតុណាមួយនោះ យើងមិនអាចទទួលខុសត្រូវឬបញ្ជូនត្រឡប់ទៅអោយម្ចាស់អត្ថបទវិញបានទេ ប្រសិនបើអ្នកនិពន្ធមិនបានផ្តល់តម្លៃសំរាប់ផ្ញើមកវិញទេនោះ។

យើងរក្សាសិទ្ធិគ្រប់យ៉ាងទៅលើអត្ថបទទាំងអស់ដែលបោះពុម្ពផ្សាយនៅក្នុងព្រឹត្តិបត្រ "ខ្មែរឡូវែល" ហើយមិនអនុញ្ញាតអោយចម្លងផ្នែកណាមួយដើម្បីយកទៅប្រើក្នុងប្រការណាមួយដោយគ្មានការអនុញ្ញាតជាលាយល័ក្ខអក្សរពីសមាគមយើងឡើយ។

**តម្លៃជាវ៖** ឆ្នាំទី ១ (មានពី ១០-១២ លេខ)
ថ្លៃ ២៥ដុល្លារ US.........(សំរាប់សហរដ្ឋអាមេរិក)
ថ្លៃ ៣០ដុល្លារ US.........(សំរាប់ប្រទេសកាណាដា)
ថ្លៃ ៤៥ ដុល្លារ US........(សំរាប់ប្រទេសផ្សេងទៀត)

**ពាណិជ្ជកម្ម៖**

ការផ្សាយពាណិជ្ជកម្មទូទៅអាចធ្វើបានទៅតាមអធ្យាស្រ័យរបស់អស់លោក។ សូមអញ្ជើញទាក់ទងលោក វ៉ាន់-វុទ្ធី, ហ៊ុត-ធារិត, ឃឿន-សំខាន់ នៅក្នុងរឿងនេះ ការិយាល័យយើង សូមពិនិត្យផ្ទៀងផ្ទាត់និងកែតម្រូវទៅលើអត្ថបទទាំងអស់ដែលយើងយល់ថា "មិនស្របនឹងគោលគំនិត" របស់ព្រឹត្តិបត្រខ្មែរឡូវែល។

រក្សាសិទ្ធិ (c) ១៩៩៧ ដោយព្រឹត្តិបត្រខ្មែរឡូវែល ។

**ការិយាល័យព្រឹត្តិបត្រខ្មែរឡូវែល**
**c\o CMAA 125 Perry Street**
**Lowell, MA 01852**
**Tel: (508) 454-4286; Fax (508) 454-1806**
**E-mail: CMAA@worldnet.att**

Khmer Lowell Newsletter is a monthly publication of the Cambodian Mutual Assistance Association of Greater Lowell, Inc. (CMAA), the Cambodian American Voter League (CAVL), and the Khmer Cultural Institute (KCI). We welcome your contribution. Send us your articles, poems, short story, opinion column, political and social commentary or any kind of art work such as cartoon that you wish to be published. All articles should be limited to 800-1200 words. Please include your name, address and phone number. We reserve the right to edit any materials for space. No part of Khmer Lowell may be reprinted or reproduced without our written permission. Subscription rate for the first year (10-12 issues) is $25.00 (USA); $30.00 (Canada) and $45.00 for all other countries. All advertising inquiries should be directed to Samkhann Khoeun, Vuthy Vann, or Thirith Hut. Copyright (c) 1997 by KhmerLowell Magazine.

**KhmerLowell Newsletter**
c/o CMAA - 125 Perry Street, Lowell, MA 01852
Tel: (508) 454-4286; Fax: (508) 454-1806
E-mail: CMAA @ worldnet.att

**Publisher/Editor**
Samkhann Khoeun

**Managing Editor**
Vuthy Vann

**Associate Editors (Khmer)**
Pahim Kay, Savy Suth, Noret Som, Vuthy Vann

**Associate Editors (English)**
Joe Nickerson, Judith D. Nelson, Chuck Sart, Seng Ty

**Arts & Cultural Editors**
Arn Chorn-Pond & Samkhann Khoeun

**Variety Editor**
Chath pierSath & Joe Nickerson

**Advertising & Marketing Managers**
Jachrey Em, Samkhann Khoeun, Seng Ty, Chuck Sart, Thirith Huth, Vuthy Vann, Noret Som & Chath Piersath

**Production Manager**
Vuthy Vann

**Editorial Assistants**
Tem Chea & Michael Ben Ho

**FAX : ( 508 ) 459 - 0044 • TEL : ( 508 ) 459 - 2575**

# ការិយាល័យច្បាប់



## យេម ដ្រាហ្គិន
## JAMES C. DRAGON



ការិយាល័យយើងខ្ញុំ ធ្លាប់បានបំរើសហគមន៍ខ្មែរច្រើនឆ្នាំមកហើយមានការ ពិសោធន៍ និងទំនុកទុកចិត្ត ព្រមទាំងមានការសរសើរពីសំណាក់បងប្អូនខ្មែរនៅគ្រប់មជ្ឈដ្ឋាន !

**មានជំនាញការខាង**

| | |
|---|---|
| ❖ គ្រោះថ្នាក់ចរាចរ | ⇨ AUTO ACCIDENT |
| ❖ គ្រោះថ្នាក់កន្លែងធ្វើការ | ⇨ WORK INJURY |
| ❖ បទឧក្រិដ្ឋកម្មផ្សេងៗ | ⇨ CRIMINAL |
| ❖ ខាតបង់ក្នុងជំនួញ | ⇨ BUSINESS LOSS |
| ❖ ច្បាប់រៀបចំជំនួញ | ⇨ BUSINESS LAW |
| ❖ ច្បាប់អន្តោប្រវេសន៍ | ⇨ IMMIGRATION |
| ❖ ធនក្ស័យ | ⇨ BANKRUPTCY |

អាស័យដ្ឋានសំរាប់ផ្ញើសំបុត្រ
P. O. Box 478
Lowell, Massachusetts 01853

អាស័យដ្ឋានការិយាល័យ
132 Warren Street
Lowell, Massachusetts 01852